## ៥

# ការរស់នៅដ៏មានជោគជ័យ
# ក្នុងជីវិតគ្រីស្ទបរិស័ទ

ប្រែក្លាយទៅជាមានជោគជ័យនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់

**សៀវភៅសំរាប់សិស្ស**

**សិក្សាជាក្រុម**

សំរាប់**គ្រិស្តបរិស័ទថ្មី**

# មាតិកា

សេចក្តីណែនាំ

**ជំពូកទី ១. តើខ្ញុំជានរណា? ........................................................៣**

ក. ព្រះជាម្ចាស់មានព្រះបន្ទូលអ្វីអំពីខ្ញុំ ........................................................៣

ខ. ខ្ញុំមានសរីរាង្គកាយ ........................................................៥

គ. ខ្ញុំមានបុគ្គលិកលក្ខណៈ ........................................................៥

ឃ. ខ្ញុំមានវិញ្ញាណ........................................................៧

**ជំពូកទី ២. ជំហ៊ាន ៥ ក្នុងការក្លាយជាគ្រីស្ទបរិស័ទដែលប្រកបទៅដោយជោគជ័យ.........៨**

ក. តើជំហ៊ានទាំង ៥ គឺជាអ្វី? ........................................................៨

១. ការក្លាយជាគ្រីស្ទបរិស័ទ ........................................................៩

២. ផ្លាស់ប្តូរវិធីដែលអ្នកគិត........................................................១០

៣. បង្កើតគោលបំណងថ្មី ........................................................១២

៤. រៀនពីរបៀបគ្រប់គ្រងអារម្មណ៏របស់អ្នក ........................................................១៧

៥. ចែកចាយជាមួយនឹងអ្នកដទៃនូវអ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់អ្នក ..........១៩

ខ. របៀបចាប់ផ្តើមប្រើជំហ៊ានទាំង ៥ ........................................................២០

**ជំពូកទី ៣. ព្រះវិញ្ញាណដ៏វិសុទ្ធ ........................................................២៣**

ក. តើនរណាគឺជាព្រះវិញ្ញាណដ៏វិសុទ្ធ? ........................................................២៣

ខ. តើព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអ្វីនៅក្នុងជីវិតរបស់អ្នក នៅពេលដែលអ្នកក្លាយទៅជាគ្រីស្ទបរិស័ទ? .............២៤

គ. តើព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអ្វីនៅក្នុងជីវិតរបស់អ្នក បន្ទាប់ពីអ្នកក្លាយទៅជាគ្រីស្ទបរិស័ទ? ..................២៧

# ជំពូក ទី ១

# តើខ្ញុំជានរណា?

តើអ្នកធ្លាប់ឆ្ងល់ថា អ្នកមានលក្ខណៈយ៉ាងដូចម្តេចដែរឬទេ? មិនមែនសរីរាង្គកាយរបស់អ្នកទេ, ប៉ុន្តែគឺជាអ្នកពិតប្រាកដខាងក្នុងចិត្តរបស់អ្នក ។ ព្រះជាម្ចាស់បានបង្កើតយើងមកជាមួយនឹងផែនការអោយយើងទាំងអស់ក្លាយជាមនុស្សពេញលក្ខណៈ ។ ប្រសិនបើយើងក្លាយទៅជាគ្រីស្តបរិស័ទដែលប្រកបទៅដោយជ័យជំនះ យើងចាំបាច់ត្រូវតែយល់ដឹងថាតើយើងជានរណា ។ ប្រសិនបើអ្នកប្រើបទដ្ឋានរបស់លោកីយ៍នៃ សំរស់ខាងរូបកាយ, លុយ និង អំណាចដើម្បីយល់ដឹងថាអ្នកជានរណានោះ, វានឹងមានការងាយស្រួលសំរាប់អ្នកបាក់ទឹកចិត្ត ។ នៅក្នុងព្រះគម្ពីរ ព្រះជាម្ចាស់មានព្រះបន្ទូលនូវកិច្ចការជាច្រើនអំពីវិធីដែលទ្រង់បានបង្កើតយើង ។ សូមអោយយើងមើលអោយកាន់តែជិតនូវអ្វីដែលព្រះអង្គគិតអំពីយើង ។

## ក. អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអ្វីអំពីខ្ញុំ

ទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយអ្នកមានឥទ្ធិពលលើអ្នកទោះជាអ្នកគ្រីស្តបរិស័ទ ឬក៏ មិនមែនគ្រីស្តបរិស័ទក៏ដោយ ។ សម្ភារៈខាងក្រោមនៅក្នុងផ្នែកនេះត្រូវបានសរសេរឡើងពីទស្សនៈដែលថាអ្នកគឺជាគ្រីស្តបរិស័ទ ។ ប្រសិនបើអ្នកមិនបានសំរេចចិត្តក្លាយជាគ្រីស្តបរិស័ទនៅឡើយទេ នោះសូមអោយអានកិច្ចការនេះ និង សួរខ្លួនឯងសំនួរនេះ " នេះគឺជារបៀបដែលខ្ញុំចង់អោយព្រះជាម្ចាស់មើលឃើញខ្ញុំនៅពេលដែលព្រះអង្គទតមើលមកខ្ញុំឬ? "

### ១. ខ្ញុំជាបុត្ររបស់ព្រះជាម្ចាស់

សូមមើល យ៉ូហាន ១:១២ និង អេភេសូ ១:៤-៥

### ២. ព្រះជាម្ចាស់ស្រលាញ់ខ្ញុំ!

សូមមើល យ៉ូហាន ៣:១៦ និង ១ យ៉ូហាន ៣:១

### ៣. ខ្ញុំមានតំលៃ

ព្រះជាម្ចាស់មានព្រះបន្ទូលថា ខ្ញុំមានតំលៃ ។ ខ្ញុំមានតំលៃជាងរបស់របរមានតំលៃនៅក្នុងលោកីយ៍នេះទៅទៀតចំពោះព្រះអង្គ ។ សូមមើល លូកា ១៥:៧-១០ និង ម៉ាថាយ ៦:២៦ ។ នៅពេលដែលព្រះយេស៊ូសុគតនៅលើឈើឆ្កាងដើម្បីលោះបាបយើង ព្រះអង្គបានបង្ហាញយ៉ាងច្បាស់ថាតើព្រះអង្គព្រួយបារម្ភចំពោះខ្ញុំប៉ុណ្ណា ។ ព្រះអង្គបានធ្វើអ្វីៗទាំងអស់ដើម្បីអោយខ្ញុំបានទៅជាមិត្តរបស់ទ្រង់ និង នៅជាមួយទ្រង់អស់កល្បជានិច្ចនៅក្នុងឋានបរមសុខ ។

### ៤. ព្រះជាម្ចាស់បានបង់ថ្លៃយ៉ាងច្រើនលើសលប់ដើម្បីទិញខ្ញុំ

ខ្ញុំជាទាសកររបស់អំពើបាប, មានទោស និង ត្រូវធ្លាក់ទៅឋាននរក ។ ប៉ុន្តែព្រះគ្រីស្តបានបានបង់ថ្លៃយ៉ាងលើសលប់ដើម្បីសេរីភាពរបស់ខ្ញុំ ។ សូមមើល ១ កូរិនថូស ៦:១៩-២០ ។

## ៥. ខ្ញុំជាអ្នកបំរើ (អ្នកដើរតាម) ព្រះគ្រីស្ទ

ទ្រង់គឺជាអ្នកដឹកនាំរបស់ខ្ញុំ ។ ខ្ញុំបំរើទ្រង់ និង ទ្រង់ប្រាប់អ្វីដែលខ្ញុំត្រូវធ្វើ ។ ខ្ញុំធ្វើអ្វីដែលទ្រង់ប្រាប់ខ្ញុំអោយធ្វើ ។ វាមិនមែនជាការទទួលខុសត្រូវរបស់ខ្ញុំប្រាប់ព្រះជាម្ចាស់អោយធ្វើនោះទេ ។ សូមមើល ១ កូរិនថូស ៦:១៩-២០ និង យ៉ូហាន ១៥:១-១១ ។

## ៦. ខ្ញុំជាមិត្តរបស់ព្រះជាម្ចាស់

ទ្រង់ស្រលាញ់ខ្ញុំ ។ ទ្រង់ហៅខ្ញុំថាជាមិត្តទ្រង់ ។ សូមមើល យ៉ូហាន ១៥:១២-១៦ ។

## ៧. ខ្ញុំនៅតែរីកចំរើន (ដូច្នេះ សូមមានការអត់ធ្មត់ជាមួយខ្ញុំ)

សូមមើល ភីលីព ១:៦

ប្រសិនបើយើងទទួលយកអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីយើងនៅក្នុងព្រះគម្ពីរ យើងយល់ដឹងថា ទ្រង់ទតមើលយើងម្នាក់ៗជាមនុស្សសំខាន់ ។ ព្រះជាម្ចាស់ស្គាល់អ្នកយ៉ាងច្បាស់ ។ ទ្រង់បានបង្កើតអ្នក និង ទ្រង់ចូលចិត្តអ្វីដែលទ្រង់បានបង្កើត ។ ឥឡូវនេះអ្នកមានអនាគតដែលពេញជាមួយនឹងឱកាសដើម្បីធ្វើអោយជីវិតរបស់អ្នកមានអត្ថន័យ និង ជោគជ័យ ពីទស្សនៈរបស់ទ្រង់ .......។

សូមអោយយើងមើលនូវវិធីដែលព្រះជាម្ចាស់បានបង្កើតយើង ។ មនុស្សពីរនាក់មិនដូចគ្នាបេះបិតនោះទេ ប៉ុន្តែយើងមានការប្រហាក់ប្រហែលគ្នាជាច្រើនយ៉ាង ។

តើខ្ញុំគឺជានរណា?

ខ. ខ្ញុំមានសរីរាង្គកាយ

១. វិញ្ញាណទាំង ៥

- ចក្ខុវិញ្ញាណ
- សោតវិញ្ញាណ
- ឃាណវិញ្ញាណ
- ជីវ្ហាវិញ្ញាណ
- កាយវិញ្ញាណ

២. កំលាំងជំរុញខាងរាង្គកាយ

- ការស្រែកឃ្លាន
- ខ្យល់

គ. ខ្ញុំមានបុគ្គលិកលក្ខណៈ

១. គំនិតរបស់ខ្ញុំ ២. អារម្មណ៍របស់ខ្ញុំ ៣. ការសំរេចចិត្តរបស់ខ្ញុំ ៤. មនសិការរបស់ខ្ញុំ

ឃ. ខ្ញុំមានវិញ្ញាណ

កន្លែងដែលព្រះជាម្ចាស់មានព្រះជន្មគង់នៅ ។រ៉ូម ៨:៩

## ខ. ខ្ញុំមានសរីរាង្គកាយ

យើងម្នាក់ៗមានសរីរាង្គកាយ : ដៃពីរ, ក្បាលមួយ, ជើងពីរ ។ល។ ពិតណាស់ យើងម្នាក់ៗមើលទៅមានភាពខុសគ្នា ។ ប៉ុន្តែ យើងទាំងអស់មានសរីរាង្គកាយដូចគ្នា ។

សរីរាង្គកាយរបស់អ្នកអាចធ្វើកិច្ចការពិសេសៗខ្លះ

- អ្នកអាចមើលឃើញជាមួយនឹងភ្នែករបស់អ្នក
- អ្នកអាចឮជាមួយនឹងត្រចៀករបស់អ្នក
- អ្នកអាចធំក្លិនជាមួយនឹងច្រមុះរបស់អ្នក
- អ្នកអាចដឹងពីរសជាតិពីអណ្តាតរបស់អ្នក
- អ្នកអាចមានអារម្មណ៍ដោយសារតែដៃ,ជើង និង ផ្នែកដទៃទៀតរបស់សរីរាង្គកាយរបស់អ្នក

សរីរាង្គកាយដែលយើងមាននេះគឺជាការអស្ចារ្យមួយ ។ គ្រប់ទាំងផ្នែកទាំងអស់ធ្វើការជាមួយគ្នា ។ វិទ្យាសាស្ត្របានស្វែងរកភាពផ្សេងៗគ្នានៃរាង្គកាយរបស់យើង និង រកឃើញថា ផ្នែកនិមួយៗមានភាពស្មុគស្មាញណាស់ ។ ព្រះជាម្ចាស់ពិតជាបានធ្វើកិច្ចការមួយដ៏ល្អអស្ចារ្យនៅពេលដែលព្រះអង្គបានបង្កើតរាង្គកាយយើងមក ។

យើងទាំងអស់គ្នាដឹងថាវាយ៉ាងម៉េចហើយនៅពេលដែលយើងឈឺ ។ សរីរាង្គកាយរបស់យើងមិនធ្វើការទៅតាមវិធីដែលព្រះជាម្ចាស់បានបង្កើតនោះទេ ។ អំពើបាបក៏មានឥទ្ធិពលនៅលើសរីរាង្គកាយរបស់យើងផងដែរ ។ ការរួមភេទក្រៅរង្វង់អាពាហ៍ពិពាហ៍នោះអាចមានផលវិបាកឆ្លងនូវជំងឺជាច្រើនរួមទាំងជំងឺអេដស៍ផងដែរ ។ ការជក់បារីនាំអោយមានជំងឺមហារីក ។ ការផឹកស្រាអាចបណ្តាលអោយកើតជំងឺថ្លើម ។

អ្នកមានសរីរាង្គកាយ ប៉ុន្តែមិនមែនត្រឹមតែមាន ឆ្អឹង, សាច់ដុំ, និង ស្បែកនោះទេ ។ អ្នកមានបុគ្គលិកលក្ខណៈ ។ អ្នកពិតប្រាកដនោះគឺមាននៅក្នុងសរីរាង្គកាយរបស់អ្នក ។

## គ. ខ្ញុំមានបុគ្គលិកលក្ខណៈ

អ្នកប្រហែលជាមើលទៅដូចជាមួយនរណាម្នាក់ខាងរូបរាង្គកាយ ជាពិសេសប្រសិនបើអ្នកជាកូនភ្លោះនោះ ។ ប៉ុន្តែ យើងម្នាក់ៗពិសេសណាស់នៅពេលដែលយើងនិយាយអំពីបុគ្គលិកលក្ខណៈនោះ ។ កិច្ចការសំខាន់ ៤ យ៉ាងដែលមានឥទ្ធិពលយ៉ាងធំសម្បើមនៅលើបុគ្គលិកលក្ខណៈរបស់យើង ។ សូមអោយយើងមើលទៅលើបុគ្គលិកលក្ខណៈទាំង ៤ នោះ ។

### ១. គំនិតរបស់ខ្ញុំ

អ្នកមានខួរក្បាល--នោះគឺជាសរីរាង្គកាយ ។ ប៉ុន្តែនៅខាងក្នុងខួរក្បាលរបស់អ្នកគឺជាគំនិត និង ការចងចាំ ។ គំនិតរបស់អ្នកធ្វើអោយអ្នកពិសេស ។ អ្វីដែលអ្នកគិតអំពីកិច្ចការពិសេសអ្វីមួយគឺជាជំនឿរបស់អ្នក ។ ឧទាហរណ៍ " ខ្ញុំជឿថាសាច់ល្អសំរាប់ខ្ញុំ ជាពិសេសសាច់ប្រឡាក់ ។ " " ខ្ញុំជឿថា មានព្រះជាម្ចាស់ និង ទ្រង់ស្រលាញ់ខ្ញុំ ។ "

អ្នកក៏បង្កើតគំរូនៃការគិតពីអតីតកាលកន្លងមកជាច្រើនឆ្នាំផងដែរ ។ ទាំងនេះយើងហៅថា អាកប្បកិរិយា ។ អ្នកមានអាកប្បកិរិយាពិតប្រាកដចំពោះការងារ--ក្រុមគំនិត និង ជំនឿទាំងមូលដែលមានឥទ្ធិពលយ៉ាងធំសម្បើមនៅលើរបៀបអ្នកប្រព្រឹត្ត និង មានអារម្មណ៍នៅពេលគេប្រាប់អោយអ្នកធ្វើកិច្ចការខ្លះ ។

## ២. អារម្មណ៍របស់ខ្ញុំ

អារម្មណ៍របស់អ្នកមានឥទ្ធិពលយ៉ាងខ្លាំងទៅលើបុគ្គលិកលក្ខណៈរបស់អ្នក ។ របៀបដែលអ្នក(ពេលណា) បង្ហាញអារម្មណ៍ របស់អ្នកប្រាប់យ៉ាងច្រើនពីបុគ្គលិកលក្ខណៈរបស់អ្នក ។ គ្មាននរណាម្នាក់ផ្សេងទៀតយល់ដឹងយ៉ាងច្បាស់លាស់ពីរបៀបអ្នក មានអារម្មណ៍ចំពោះស្ថានភាពដែលជួបប្រទះនោះទេ ។ ប៉ុន្តែពួកគេអាចមានគំនិតល្អ១ ពីព្រោះដោយសារតែពួកគេមាន អារម្មណ៍ដូចគ្នាទៅនឹងអារម្មណ៍ដែលអ្នកមាន--កំហឹង, អំណរ, ទុក្ខព្រួយ, សេចក្តីសុខសាន្ត, សេចក្តីភ័យខ្លាច ។

## ៣. ការសំរេចចិត្តរបស់ខ្ញុំ

អ្នកមានឆន្ទៈ ។ អ្នកអាចធ្វើការសំរេចចិត្តដោយខ្លួនអ្នកផ្ទាល់ ។ ផ្នែកនេះនៃបុគ្គលិករបស់អ្នកគឺពិសេសណាស់ចំពោះអ្នក ។ ព្រះជាម្ចាស់បានបង្កើតយើងម្នាក់ៗដោយទ្រង់បានផ្តល់នូវលទ្ធភាពអោយយើងធ្វើការសំរេចចិត្ត ។ មនុស្សដទៃទៀតអាចមានឥទ្ធិពលមកលើយើង ប៉ុន្តែយើងនៅតែមានអំណាចអាចសំរេចចិត្តនូវអ្វីដែលយើងត្រូវធ្វើដដែល ។ សំរាប់មនុស្សខ្លះក្នុងចំណោមយើង កិច្ចការនេះអាចនាំអោយយើងមានបញ្ហាជាមួយនឹងប៉ូលីស ។ យើងបដិសេធនឹង និង មិនស្តាប់បង្គាប់ច្បាប់ដែល មនុស្សដទៃបង្កើតឡើង ។ មនុស្សខ្លះក្នុងចំណោមយើងអាចជាប់នៅក្នុងនោះ ។

ព្រះជាម្ចាស់ផ្តល់នូវការទទួលខុសត្រូវដល់យើងសំរាប់ការសំរេចចិត្តដែលយើងធ្វើឡើង ។ យើងមិនអាចបន្ទោសនរណាម្នាក់ផ្សេងទៀតសំរាប់ការសំរេចចិត្តដែលយើងបានធ្វើឡើងនោះទេ ។ យើងត្រូវតែប្រឈមមុខចំពោះផលវិបាកនៃការសំរេចចិត្តរបស់យើង ប្រសិនបើកិច្ចការនោះវាបែរជាកើតឡើងមិនទៅតាមអ្វីដែលយើងបានរំពឹងគិតនោះ ។

## ៤. មនសិការ របស់ខ្ញុំ

សត្វមានលទ្ធភាពអាចគិត, ទទួលអារម្មណ៍ និង ធ្វើការសំរេចចិត្តបានមានសត្វខ្លះឆ្លាតណាស់ ។ ប៉ុន្តែព្រះជាម្ចាស់បានបង្កើតមនុស្សអោយមានលក្ខណៈខុសផ្លែកពីសត្វដោយទ្រង់បានផ្តល់អោយមនុស្សមានមនសិការ ។ នេះគឺជាផ្នែកមួយរបស់អ្នកដែលប្រាប់អ្នកនៅពេលដែលអ្នកនឹងធ្វើអ្វីមួយខុស ឬក៏ ត្រូវនោះ ។

ជារឿយ១យើងតែងតែនិយាយពីមនសិការច្បាស់លាស់ និង មនសិការខុស ។ តើអ្នកមានអារម្មណ៍មិនល្អឬទេ នៅពេលដែលអ្នកដឹងថាអ្នកបានធ្វើអ្វីមួយខុសនោះ? ប្រសិនបើអ្នកមានអារម្មណ៍មិនល្អនៅខាងក្នុង ហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ? ដោយសារតែមនសិការរបស់អ្នកប្រាប់អ្នកអំពីកិច្ចការនេះ ។

នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សមក ព្រះជាម្ចាស់បានដាក់នូវមនសិការដល់យើងម្នាក់ៗដូច្នេះយើងនឹងមានលេសសំរាប់ធ្វើអំពើបាបនោះទេ ។ មនុស្សខ្លះបានបាត់បង់នូវមនសិការរបស់ពួកគេ ។ មនុស្សជាច្រើនដែលមិនមែនជាគ្រីស្តបរិស័ទបដិសេធនឹងស្តាប់នូវមនសិការរបស់ផ្ទាល់របស់ពួកគេ ។

ប្រសិនបើអ្នកមានការលំបាកស្តាប់ព្រះជាម្ចាស់នៅពេលទ្រង់មានព្រះបន្ទូលតាមរយៈមនសិការរបស់អ្នកនោះ សូមអធិស្ឋាន និង សុំអោយព្រះជាម្ចាស់ជួយអ្នកអោយឆាប់យល់ដឹងចំពោះមនសិការរបស់អ្នក ។ សូមរៀនស្តាប់មនសិការរបស់អ្នក និង ស្តាប់បង្គាប់វាភ្លាម១ ។ មនសិការរបស់អ្នកអាចការពារអ្នកមិនអោយធ្វើតាមការល្បួង ។

ប្រសិនបើអ្នកមានមនសិការខុស សូមអធិស្ឋាន និង សារភាពអំពើបាបរបស់អ្នកដល់ព្រះជាម្ចាស់ ។ ទ្រង់នឹងអត់ទោសអោយអ្នកហើយយកកំហុសនោះចេញ ។ ទ្រង់នឹងផ្តល់អោយអ្នកនូវមនសិការច្បាស់លាស់មួយដែលពេញទៅដោយសេចក្តីសុខសាន្ត ។

អ្នកត្រូវតែប្រុងប្រយត្ន័មិនត្រូវរំលោភមនសិការរបស់អ្នកបន្ទាប់ពីអ្នកក្លាយទៅជាគ្រីស្តបរិស័ទនោះទេ ។ អ្នកមានការទទួលខុសត្រូវក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់នៅពេលទ្រង់មានព្រះបន្ទូលមកកាន់អ្នក ។

## ឃ. ខ្ញុំមានវិញ្ញាណ

យើងអាចនិយាយផងដែរថា " វិញ្ញាណនៅក្នុងខ្ញុំ " អ្នកមិនត្រឹមតែមានសរីរាង្គកាយ និង បុគ្គលិកលក្ខណៈប៉ុណ្ណោះនោះទេ ។ នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្សមក ទ្រង់បានបង្កើតយើងមកដូចរូបអង្គទ្រង់ផ្ទាល់ ។ ព្រះជាម្ចាស់ទ្រង់គឺជាវិញ្ញាណ ។ ព្រះជាម្ចាស់បានផ្តល់អោយយើងម្នាក់ៗនូវវិញ្ញាណនោះ ។

នៅពេលដែលមនុស្សម្នាក់ក្លាយទៅជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់មករស់នៅក្នុងជីវិតរបស់ពួកគេ ។ តើរស់នៅកន្លែងណា? នៅក្នុងខួរក្បាលរបស់ពួកគេ? មិនមែនទេ ។ នៅក្នុងចិត្តរបស់ពួកគេ? មិនមែនទេ នោះគ្រាន់តែជាប្រដាប់បូមឈាមប៉ុណ្ណោះ ។ នៅក្នុងអារម្មណ៏របស់អ្នក? មិនមែនទេ ។ នៅពេលដែលមនុស្សម្នាក់ក្លាយទៅជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់មករស់នៅក្នុងវិញ្ញាណរបស់ពួកគេ ។ តើវិញ្ញាណរបស់ពួកគេនៅឯណា? វានៅក្នុងអ្នក ប៉ុន្តែមិនមែនសរីរាង្គកាយរបស់អ្នកនោះទេ ។ ប៉ុន្តែវាមានពិតប្រាកដ ។ អារម្មណ៍នៃការខឹង, ភ័យខ្លាច, អំណរ និង សេចក្តីសុខសាន្តវាមានពិតប្រាកដមែន ប៉ុន្តែវាមិនមែនជាសរីរាង្គកាយរបស់អ្នកនោះទេ ។ អ្នកមិនអាចវះកាត់មនុស្សបើករកមើលកំហឹង ឬក៏ ការភ័យខ្លាចនៅខាងក្នុងមនុស្សនោះទេ ។ ប៉ុន្តែអារម្មណ៏ទាំងនោះនៅតែជាផ្នែកមួយដែលមានពិតប្រាកដនៅខាងក្នុងយើងម្នាក់ៗ ។ រ៉ូម ៨:៩-១១ និយាយថា ព្រះជាម្ចាស់រស់នៅខាងក្នុងវិញ្ញាណរបស់យើង ។

អំពើបាបបំផ្លាយជីវិតរបស់យើង ។ មនុស្សដែលកំពុងរស់នៅក្នុងអំពើបាប( មនុស្សដែលមិនមែនជាគ្រីស្តបរិស័ទ)គឺខាងព្រលឹងវិញ្ញាណរបស់ពួកគេស្លាប់ ។ ព្រះជាម្ចាស់មិនរស់នៅខាងក្នុងពួកគេនោះទេ ។ ប៉ុន្តែនៅពេលដែលអ្នកមករកព្រះគ្រីស្ត និង ថ្វាយជីវិតរបស់អ្នកដល់ទ្រង់ ទ្រង់ផ្តល់ជីវិតដល់វិញ្ញាណរបស់អ្នក ហើយទ្រង់មកគង់នៅក្នុងជីវិតរបស់អ្នក ។

នៅពេលដែលសរីរាងកាយរបស់អ្នកស្លាប់ទៅ វិញ្ញាណរបស់អ្នកនឹងទៅឋានសួគ៌ ហើយអ្នកនឹងរស់នៅជាមួយនឹងព្រះជាម្ចាស់អស់កល្បជានិច្ច ។

# ជំពូក ទី ២

# ជំហ៊ាន ៥ ក្នុងការក្លាយជាគ្រីស្ទបរិស័ទដែលប្រកបទៅដោយជោគជ័យ

មនុស្សខ្លះមានគំនិតថា វាងាយស្រួលណាស់ក្នុងការក្លាយទៅជាគ្រីស្ទបរិស័ទប្រកបដោយជោគជ័យនោះ ។ ពួកគេគិតថានៅពេលដែលអ្នកសារភាពអំពើបាបរបស់អ្នក ព្រះជាម្ចាស់នឹងដកយកចេញនូវបញ្ហារបស់អ្នកដោយស្វ័យប្រវត្តហើយផ្តល់អោយអ្នកនូវអំណរ, សេចក្តីសុខសាន្ត និង លុយកាក់ ។ ព្រះជាម្ចាស់មិនធ្វើកិច្ចការទៅតាមវិធីនោះ នោះទេ ។ ប្រសិនបើអ្នកចង់ក្លាយទៅជាគ្រីស្ទបរិស័ទប្រកបទៅដោយជោគជ័យនោះ អ្នកត្រូវតែធ្វើកិច្ចការជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីនាំឱ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់អ្នក ។

ព្រះវិញ្ញាណដ៏វិសុទ្ធនឹងណែនាំអ្នកតាមរយៈបទពិសោធន៍ប្រចាំថ្ងៃរបស់អ្នក និង ផ្តល់អោយអ្នកនូវឱកាសក្នុងការរីកចំរើនខាងព្រលឹងវិញ្ញាណកាន់តែខ្លាំងឡើង ។ អ្នកមិនក្លាយទៅជាគ្រីស្ទបរិស័ទចាស់ទុំក្នុងមួយ ឬក៏ ពីរសប្តាហ៍នោះទេ ។ ដោយមានជំនួយមកពីព្រះជាម្ចាស់ អ្នកអាចបន្តរីកចំរើនរហូតដល់ថ្ងៃដែលអ្នកស្លាប់ ។ ព្រះជាម្ចាស់វាស់វែងជោគជ័យផ្សេងពីមនុស្សវាស់វែង ។ អ្នកអាចជោគជ័យថ្ងៃនេះតាមព្រះនេត្ររបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកធ្វើកិច្ចការដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើនៅថ្ងៃនេះ ។ សូមចាំថា អ្នកគឺជាកូនរបស់ព្រះជាម្ចាស់ ។

ប្រសិនបើអ្នកមានកូនដែលមានអាយុ ពី ១ឆ្នាំ ទៅ ២ឆ្នាំ កូននោះវាធ្វើសកម្មភាពដូចគ្នាទៅនឹងកូនដទៃទៀតដែរ ។ អ្នកនឹងមិនខឹងដោយវាមិនធ្វើសកម្មភាពដូចមនុស្សធំនោះទេ ។ ប៉ុន្តែនៅពេលដែលកូនរបស់អ្នក មានអាយុ ២១ឆ្នាំ អ្នកចង់អោយវាមានឥរិយាបថ និង ការនិយាយស្តីដូចមនុស្សធំពេញវ័យ ។ នៅពេលដែលព្រះជាម្ចាស់ទតមើលអ្នក ព្រះជាម្ចាស់ប្រើបទដ្ឋានមួយយុតិធម៌ និង ត្រឹមត្រូវ ។ ព្រះអង្គយល់ដឹងនូវកំលាំង និង ភាពទន់ខ្សោយរបស់អ្នក ហើយនឹងការរីកចំរើនប៉ុណ្ណាដែលព្រះជាម្ចាស់ចង់បានពីអ្នក ។ ប្រសិនបើអ្នកពិតជាចង់ក្លាយទៅជាគ្រីស្ទបរិស័ទដែលប្រកបទៅដោយជោគជ័យ អ្នកត្រូវតែបន្តរីកចំរើនតទៅទៀត ។

នៅទំព័រខាងក្រោមនេះអ្នកនឹងរកឃើញនូវជំហ៊ា ៥ នៃការរីកចំរើនដែលអាចជួយអ្នកអោយក្លាយទៅជាគ្រីស្ទបរិសទចាស់ទុំបាន ។ យើងអាចបន្ថែមអោយកាន់តែច្បាស់លាស់ថែមទៀតនូវបញ្ជីដែលបង្ហាញពីជំហានដែលទាក់ទងនៅក្នុងដំណើរការរីកចំរើននេះ ។ ប៉ុន្តែ ជំហ៊ានទាំង ៥នេះគឺជាមូលដ្ឋានដែលយើងម្នាក់ៗត្រូវតែគិតអោយបានច្បាស់លាស់ នៅពេលយើងព្យាយាមគាប់ព្រះហឫទ័យទ្រង់ ។

## ក. តើជំហ៊ានទាំង ៥ គឺជាអ្វី?

១. ក្លាយទៅជាគ្រីស្ទបរិស័ទ

២. ផ្លាស់ប្តូរវិធីដែលអ្នកគិត

៣. បង្កើតគោលដៅថ្មី

៤. រៀនពីរបៀបគ្រប់គ្រងអារម្មណ៍របស់អ្នក

៥. ចែកចាយជាមួយនឹងអ្នកដទៃនូវអ្វីដែលព្រះគ្រីស្ទបានធ្វើនៅក្នុងជីវិតរបស់អ្នក

សូមអោយយើងមើលអោយកាន់តែច្បាស់នូវជំហ៊ានទីមួយៗទាំង ៥ នេះ ។

## ជំហាន ទី ១.  ក្លាយទៅជាគ្រីស្ទបរិស័ទ

វាច្បាស់លាស់ណាស់ថា មនុស្សម្នាក់មិនអាចក្លាយទៅជាគ្រីស្ទបរិស័ទប្រកបដោយជោគជ័យបាននោះទេ រហូតទាល់តែគាត់ក្លាយទៅជាគ្រីស្ទបរិស័ទសិន ។ ព្រះគម្ពីរសួរសំនួរនេះដើម្បីជួយអោយយើងគិតនូវអាទិភាពរបស់យើងនៅក្នុងជីវិត ។ " បើមនុស្សម្នាក់បានលោកីយ៍ទាំងមូល មកធ្វើជាសម្បត្តិរបស់ខ្លួន តែបាត់បង់ជីវិតនោះនឹងមានប្រយោជន៍អ្វី? តើមនុស្សអាចយកអ្វីមកប្តូរនឹងជីវិតរបស់ខ្លួនបាន? " (ម៉ាកុស ៨:៣៦-៣៧) នៅពេលដែលអ្នកមើលពិភពលោកនេះទាំងមូលបានផ្តល់សំរាប់ឆាកជីវិតរស់នៅរបស់អ្នក តើវាមានតំលៃជាងក្នុងការចំណាយជីវិតអស់កល្បជាមួយព្រះជាម្ចាស់?

តើការក្លាយជាគ្រីស្ទបរិស័ទមានអ្វីជាប់ទាក់ទង? តើវិញ្ញាណ, ចិត្តគំនិត, អារម្មណ៍ និង ឆន្ទះជាប់ទាក់ទងដោយរបៀបណានៅក្នុងដំណើរការនៃការក្លាយជាគ្រីស្ទបរិស័ទ ។

### ក.  សូមអោយព្រះជាម្ចាស់មានបន្ទូលមកកាន់អ្នកតាមរយៈព្រះគម្ពីរ

ព្រះជាម្ចាស់បានផ្តល់អោយយើងនូវព្រះបន្ទូលរបស់ទ្រង់គឺព្រះគម្ពីរ ដែលប្រាប់យើងពីរបៀបក្លាយទៅជាគ្រីស្ទបរិស័ទ ។ នៅពេលដែលអ្នកអានព្រះគម្ពីរ អ្នកនឹងអាចមើលឃើញច្បាស់លាស់នូវសេចក្តីពិតដែលពន្យល់ពីរបៀបមនុស្សម្នាក់អាចក្លាយទៅជាគ្រីស្ទបរិស័ទ ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងមានព្រះបន្ទូលមកកាន់អ្នកតាមរយៈមនសិការរបស់អ្នក និង បង្ហាញអ្នកថាតើហេតុអ្វីបានជាអ្នកត្រូវតែក្លាយជាគ្រីស្ទបរិស័ទ ។ នៅពេលដែលអ្នកថ្វាយជីវិតរបស់អ្នកទៅដល់ព្រះគ្រីស្ទ ទ្រង់យាងមកគង់ នៅក្នុងវិញ្ញាណរបស់អ្នក ។ ទ្រង់ផ្តល់ជីវិតដល់វិញ្ញាណរបស់អ្នក ។ សូមមើល រ៉ូម ៨:៩-១១ ។

### ខ.  អ្នកយល់ដឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយនឹងគិតគំនិតរបស់អ្នក

ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកអោយយល់ដឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ព្រះអង្គនឹងជួយអ្នកអោយមើលឃើញពីរបៀបអ្នកអាចក្លាយទៅជាគ្រីស្ទបរិស័ទ ។ អ្នកត្រូវតែយល់ដឹងពីរបៀបក្លាយទៅជាគ្រីស្ទបរិស័ទ មុននឹងអាចក្លាយទៅជាគ្រីស្ទបរិស័ទ ។ វាមិនអាចកើតឡើងនោះទេក្នុងការប្រើល្បិចដើម្បីអោយក្លាយជាគ្រីស្ទបរិស័ទនោះ ។ ចិត្តគំនិតរបស់អ្នកត្រូវតែជាប់ទាក់ទងយ៉ាងសកម្មនៅពេលដែលអ្នកក្លាយទៅជាគ្រីស្ទបរិស័ទ ។

### គ.  អ្នកឆ្លើយតបជាមួយនឹងអារម្មណ៍របស់អ្នក

នៅពេលដែលអ្នកក្លាយទៅជាគ្រីស្ទបរិស័ទ អារម្មណ៍របស់អ្នកគួរតែជាប់ទាក់ទងយ៉ាងសកម្ម ។ នេះគឺជាអារម្មណ៍ខ្លះៗដែលមនុស្សម្នាក់ៗពិសោធន៍នៅពេលក្លាយជាគ្រីស្ទបរិស័ទ ។

ទុក្ខព្រួយ--ដោយសារតែអ្នកបានធ្វើបាបជំទាស់នឹងព្រះជាម្ចាស់ ។ សូមមើល យ៉ាកុប ៤:៩ ។ អំណរ--ដោយសារតែព្រះជាម្ចាស់បានអត់ទោសអំពើបាបរបស់អ្នក ។ អ្នកអាចមានអំណរដោយសារតែអ្នកឥឡូវនេះក្លាយទៅជាបុត្ររបស់ព្រះជាម្ចាស់ និង ទ្រង់សន្យាថាផ្តល់នូវជីវិតអស់កល្បជាមួយនឹងព្រះជាម្ចាស់ ។ សូមមើល លូកា ១០:២០ ។ សេចក្តីសុខសាន្ត--ដោយសារតែព្រះគ្រីស្ទគឺជាអ្នកដឹកនាំនៃជីវិតរបស់អ្នក ។ សូមមើល យ៉ូហាន ១៤:២ ។

### ឃ.  អ្នកជ្រើសរើសជាមួយនឹងឆន្ទះរបស់អ្នក

អ្នកត្រូវតែធ្វើច្រើនជាគិតអំពីការក្លាយជាគ្រីស្ទបរស័ទឬក៏ ពិសោធន៍ខាងអារម្មណ៍--អ្នកត្រូវតែធ្វើការសំរេចចិត្ត ។ អ្នកត្រូវតែសំរេចចិត្តនូវអ្វីដែលអ្នកនឹងធ្វើជាមួយនឹងព្រះជាម្ចាស់ ។ តើអ្នកនឹងជ្រើសរើសសារភាពអំពើបាបរបស់អ្នក និង សុំអោយទ្រង់អត់អោយអ្នក? តើអ្នកនឹងអោយទ្រង់ក្លាយជាអ្នកដឹកនាំក្នុងជីវិតរបស់អ្នកឬទេ? ប្រសិនបើអ្នកឆ្លើយសំនួរនេះថា " បាទ ខ្ញុំចង់ធ្វើដូចនេះ " នោះអ្នកត្រូវតែប្រាប់ព្រះជាម្ចាស់នូវការសំរេចចិត្តរបស់អ្នក ។ សូមមើល រ៉ូម ១០:៩-១០ ។

នៅពេលដែលអ្នកសុំអោយព្រះគ្រីស្ទអត់ទោសអោយអំពើបាបរបស់អ្នក និង សុំអោយទ្រង់ក្លាយទៅជាអ្នកដឹកនាំក្នុងជីវិតរបស់អ្នក--ទ្រង់នឹងធ្វើកិច្ចការនេះ! ទ្រង់មករស់នៅក្នុងវិញ្ញាណរបស់អ្នក--ព្រះអង្គរស់នៅទីនោះ! សូមមើល រ៉ូម ៨:៩-១១ ។ ប្រធានបទទាំងមូលនៃការក្លាយទៅជាគ្រីស្ទបរិស័ទត្រូវបានពិភាក្សាយ៉ាងពិស្តារនៅក្នុង ការសិក្សាជាក្រុមសំរាប់គ្រីស្ទបរិស័ទថ្មីដែលមានចំណងជើងថា <u>*តើខ្ញុំអាចដឹងថា ខ្ញុំជាគ្រីស្ទបរិស័ទដោយរបៀបណា?*</u>

## **ជំហ៊ាន ទី ២. ផ្លាស់ប្តូរវិធីដែលអ្នកគិត**

មនុស្សខ្លះគិតថាការសារភាពអំពើបាបរបស់ពួកគេ និង សុំអោយព្រះគ្រីស្ទក្លាយទៅជាអ្នកដឹកនាំនៃជីវិតរបស់ពួកគេ នោះគឺជាអ្វីដែលពួកគេត្រូវធ្វើដើម្បីក្លាយជាគ្រីស្ទបរិស័ទប្រកបទៅដោយជោគជ័យ ។ វាមិនស្រួលដូចនោះទេ ។ នៅពេលដែលអ្នកក្លាយជាគ្រីស្ទបរិស័ទ ព្រះជាម្ចាស់ផ្លាស់ប្តូរវិញ្ញាណរបស់អ្នកភ្លាម១ ។ ទ្រង់យាងមកគង់នៅក្នុងវិញ្ញាណរបស់អ្នក ។ ប្រសិនបើគ្មានវត្តមានរបស់ព្រះជាម្ចាស់ទេ មិនន័យថា វិញ្ញាណនោះស្លាប់ ។

ប៉ុន្តែព្រះជាម្ចាស់មិនផ្លាស់ប្តូរចិត្តគំនិត, អារម្មណ៍ និង ឆន្ទះរបស់អ្នកភ្លាម១នោះទេ ។ អ្នកត្រូវតែចូលរួមយ៉ាងសកម្មក្នុងការផ្លាស់ប្តូរកន្លែងទាំងនេះនៃជីវិតរបស់អ្នកប្រសិនបើចង់ក្លាយទៅជាគ្រីស្ទបរិស័ទប្រកបដោយជោគជ័យនោះ ។

ព្រះជាម្ចាស់មានព្រះបន្ទូលនៅក្នុងអេសាយ ៥៥:៨ថា គំនិតយើងខុសប្លែកពីគំនិតអ្នករាល់គ្នា រីឯរបៀបដែលយើងប្រព្រឹត្តក៏ខុសប្លែកពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្តដែរ ។ អ្នកត្រូវតែរៀនគិតទៅតាមវិធីដែលព្រះជាម្ចាស់គិត ។ ភីលីព ៤:៨ ផ្តល់នូវឧទាហរណ៍ពីរបៀបព្រះជាម្ចាស់ចង់អោយអ្នកគិត ។ នៅពេលដែលអ្នកសិក្សាព្រះគម្ពីរ និង អនុវត្តន៍នូវអ្វីដែលអ្នកបានរៀន ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកអោយយល់ដឹងពីរបៀបដែលទ្រង់គិត ទ្រង់នឹងជួយអ្នកអោយផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នក ។ រ៉ូម ១២:២ ជំរុញអោយយើងរៀនវិធីនៃការគិតថ្មី១ទាំងមូល ។

រ៉ូម ១២:២

មិនត្រូវយកគំរាប់តាមលោកីយ៍នេះឡើយត្រូវទុកអោយព្រះជាម្ចាស់កែប្រែចិត្តគំនិតបងប្អូនអោយទៅជាថ្មីទាំងស្រុងវិញដើម្បីឱ្យបងប្អូនចេះពិចារណាមើលថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះគឺអ្វីដែលល្អដែលគាប់ព្រះហឫទ័យព្រះអង្គ និង គ្រប់លក្ខណៈ ។

### **ក. តើអាកប្បកិរិយាគឺជាអ្វី?**

អាកប្បកិរិយាមិនមែនជាអារម្មណ៍នោះទេ ។ អារម្មណ៍មិនដូចគ្នាទៅនឹងគំនិតនោះទេ ។ ការប្រកាន់ពូជសាសន៍គឺជាអាកប្បកិរិយា ។ វាទាក់ទងទៅនឹងអ្វីដែលអ្នកគិតពីកិច្ចការពិសេសមួយ ។ អ្នកអាចមានអារម្មណ៍ខ្លាំងក្លាដោយភ្ជាប់ជាមួយនឹងអាកប្បកិរិយានៃការប្រកាន់ពូជសាសន៍របស់អ្នក ដូចជា កំហឹង, សំអប់ ឬក៏ ការភ័យខ្លាច ។

នេះគឺជានិយមន័យខ្លះ១នៃពាក្យ " អាកប្បកិរិយា "

(១) គំរូនៃការគិត

(២) ទំលាប់នៃការគិត

(៣ គំនិតនឹងន

(៤) ទស្សនៈយោបល់

(៥) ប្រភពព័ត៌មាន

អាកប្បកិរិយាត្រូវបានបង្កើតឡើងនៅក្នុងចិត្តគំនិតរបស់អ្នក និង ក្លាយទៅជាផ្នែកយ៉ាងច្រើននៅក្នុងជីវិតរបស់អ្នក ដែលសូម្បីតែនៅពេលដែលអ្នកប្រើវា អ្នកមិនទាំងគិតអំពីវាផងដែរ ។ អ្នកបង្ហាញអាកប្បកិរិយារបស់អ្នកដោយរបៀបអ្នកឆ្លើយតបនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក ។ អ្វីដែលអ្នកនិយាយ និង ធ្វើ និង អារម្មណ៍ដែលអ្នកបង្ហាញបញ្ចេញអោយឃើញអាកប្បកិរិយារបស់អ្នក ។ តើអ្នកមានប្រតិកម្មយ៉ាងដូចម្តេច នៅពេលដែលអ្នកបើកឡានខាងមុខរបស់អ្នកឈប់ហើយនៅពេលនោះភ្លើងចរាចរណ៍ពណ៌បៃតង? តើអ្នកមានប្រតិកម្មយ៉ាងដូចម្តេចនៅពេលនរណាម្នាក់ដាក់បណ្តាសារអ្នក ឬក៏ ហៅឈ្មោះអ្នកដោយពាក្យមិនពិរោះស្តាប់នោះ ។ ប្រតិកម្មរបស់អ្នកបង្ហាញអាកប្បកិរិយារបស់អ្នក--គំនិតគំរូនៅក្នុងចិត្តគំនិតរបស់អ្នកចំពោះស្ថានភាពនីមួយៗ ។

## ខ. តើខ្ញុំអាចបង្កើតអាកប្បកិរិយាថ្មីដោយរបៀបណា?

ជួនកាលដំណើរការនៃការបង្កើតអាកប្បកិរិយាថ្មីមានភាពយឺតយ៉ាវ និង មានការលំបាក ។ អ្នកប្រហែលជាចង់បញ្ឈប់ប្រតិកម្មភ្លាមៗជាមួយនឹងកំហឹងនៅពេលនរណាម្នាក់ខឹងអ្នក ។ កិច្ចការនេះតំរូវអោយអនុវត្តច្រើនជាងគ្រាន់តែសន្យាផ្លាស់ប្តូរចំពោះខ្លួនអ្នកផ្ទាល់ ។ អាកប្បកិរិយាទាំងនេះគឺជាផ្នែកមួយនៃវិធីដែលអ្នកគិតអស់ជាច្រើនឆ្នាំមកហើយ ។ ព្រះជាម្ចាស់កំរនឹងផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកភ្លាមៗនោះណាស់ ។ ប៉ុន្តែជាធម្មតាព្រះជាម្ចាស់មិនសំដែងអោយឃើញការអស្ចារ្យនៅក្នុងកន្លែងនេះនៃជីវិតរបស់អ្នកនោះទេ ។ ប៉ុន្តែ អ្នកអាចមានការប្រាកដនៅក្នុងចិត្តថា ទ្រង់រៀបចំខ្លួនរួចជាស្រេចដើម្បីជួយអ្នកអោយផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នក ប្រសិនបើអ្នកសុខចិត្តធ្វើការជាមួយនឹងទ្រង់ ។

វិធីដ៏ល្អបំផុតដើម្បីរកអោយឃើញអាកប្បកិរិយាថ្មីដែលព្រះជាម្ចាស់ចង់អោយអ្នកមានគឺអ្នកត្រូវតែអានព្រះគម្ពីរ ។ សូមរកអោយឃើញពីរបៀបព្រះយេស៊ូគ្រីស្ទមានប្រតិកម្មចំពោះមនុស្សផ្សេងៗគ្នាដែលទ្រង់បានជួប និង បានធ្វើការជាមួយនៅក្នុងថ្ងៃនីមួយៗ ។ សូមស្វែងរកអត្ថបទព្រះគម្ពីរដែលនិយាយអំពីកន្លែងនៅក្នុងជីវិតរបស់អ្នកដែលអ្នកត្រូវការផ្លាស់ប្តូរវិធីនៃការគិតរបស់អ្នក ។ កណ្ឌគម្ពីរសុភាសិតគឺជាកណ្ឌគម្ពីរមួយដ៏ល្អដើម្បីរកអោយឃើញពីរបៀបព្រះជាម្ចាស់គិតអំពីបញ្ហាផ្សេងៗគ្នាជាច្រើនដែលអ្នកប្រឈមមុខនៅក្នុងជីវិតរបស់អ្នក ។ ភីលីព ២:៥ លើកទឹកចិត្តអោយយើងបង្កើតអោយមានអាកប្បកិរិយាដូចព្រះគ្រីស្ទមាន ។ ប្រសិនបើអ្នកមិនប្រាកដថា អាកប្បកិរិយារបស់អ្នកមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់នោះសូមសួរព្រះអង្គ " ព្រះជាម្ចាស់ តើព្រះជាម្ចាស់គិតយ៉ាងដូចម្តេចអំពីកិច្ចការនេះ? សូមស្វែងរកចំលើយរបស់ទ្រង់នៅពេលដែលអ្នកអានព្រះគម្ពីរ និង និយាយទៅកាន់គ្រីស្តបរិស័ទដទៃទៀត ។

គ្រាន់តែអានព្រះគម្ពីរមិនគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរវិធីនៃការគិតរបស់អ្នកនោះទេ ។ ការចងចាំអត្ថបទព្រះគម្ពីរគឺជាវិធីមួយដ៏មានអំណាចដើម្បីជួយអ្នកបង្កើតនូវអាកប្បកិរិយាថ្មីនៅក្នុងជីវិតរស់នៅរបស់អ្នក ។ លូកា ៦:២៧-៣៨ ពេញជាមួយនឹង ខ សំខាន់ៗ ។ នៅពេលដែលអ្នកចងចាំខគម្ពីរ សូមប្រាប់ខ្លួនឯងថានេះគឺជារបៀបអ្នកចង់គិត ។

សូមចងចាំថាការបង្កើតអាកប្បកិរិយាថ្មីនៅក្នុងជីវិតរបស់អ្នកប្រហែលជាមិនទទួលជោគជ័យនោះទេ ប្រសិនបើអ្នកពឹងផ្អែកទៅលើអំណាចផ្ទាល់របស់អ្នក ។ សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកអោយអនុវត្តនៅអាកប្បកិរិយាខាងព្រះគម្ពីរទាំងនេះនៅក្នុងគ្រប់ទាំងស្ថានភាពទាំងអស់ ។ សូមមើល យ៉ូហាន ១៦:១៣ ។ មុខវិជ្ជាអាកប្បកិរិយាត្រូវបានពន្យល់យ៉ាងពិស្តារនៅក្នុងការសិក្សាជាក្រុមសំរាប់គ្រីស្តបរិស័ទដែលមានចំណងជើងថា អាកប្បកិរិយា ។

## ជំហាន ទី ៣.    បង្កើតគោលដៅថ្មី

ការក្លាយជាគ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យ ទាក់ទងច្រើនជាងគ្រាន់តែយល់ដឹងពីព្រះបន្ទូលរបស់ ព្រះជាម្ចាស់ ។ អ្នកត្រូវអនុវត្តវានៅក្នុងជីវិតរបស់អ្នក ។ អ្នកត្រូវតែដាក់អោយឆន្ទៈ និង ចំណង់របស់អ្នកនៅខាងក្រោម ការដឹកនាំរបស់ព្រះជាម្ចាស់ និង ធ្វើអ្វីៗដែលទ្រង់ចង់អោយអ្នកធ្វើ ។ សុភាសិត ១៦:៩ និយាយថា " មនុស្សគិតគូរពីផ្លូវដែលខ្លួនត្រូវដើរ តែព្រះជាម្ចាស់ជាអ្នកណែនាំផ្លូវ ។ " បង្កើតគោលដៅរបស់អ្នកអោយដូចគ្នាទៅនឹងផែនការ និងគោលដៅដែលព្រះជាម្ចាស់មានសំរាប់អ្នក ហើយអ្នកសួរសំនួរនេះដល់ព្រះជាម្ចាស់ " តើព្រះជាម្ចាស់ចង់អោយទូលបង្គំធ្វើអ្វី? "

### ក.    រកអោយឃើញនូវអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ

ជំហ៊ានដំបូង និង សំខាន់បំផុតក្នុងការបង្កើតគោលដៅគឺត្រូវរកអោយឃើញនូវអ្វីជាផែនការរបស់ព្រះជាម្ចាស់សំរាប់អ្នក ។ សិក្សាព្រះគម្ពីរដើម្បីអោយយល់ដឹងនូវអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ ។ មានខគម្ពីរជាច្រើនដែលទាក់ទងជាមួយនឹងស្ថានភាពដែលអ្នកប្រឈមមុខជារៀងរាល់ថ្ងៃ ។ សូមប្រើពាក្យស្របគ្នាក្នុងព្រះគម្ពីរដើម្បីស្វែងរកខគម្ពីរទាំងអស់ដែលនិយាយអំពីប្រធានបទពិសេសណាមួយ ។

ឧទាហរណ៍ អ្នកនឹងរកឃើញនូវខគម្ពីរជាច្រើនដែលបង្ហាញអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ នៅពេលដែលអ្នកកំពុងតែធ្វើការ ។ ខ គម្ពីរដទៃទៀតទាក់ទងជាមួយនឹង ការនិយាយ និង អារម្មណ៍របស់អ្នកដូចជា កំហឹង, ភាពល្ងឹងជូរចត់, អំណរ និង សេចក្តីសុខសាន្ត ។ នៅក្នុង ខ គម្ពីរទាំងនេះ ព្រះជាម្ចាស់ប្រាប់អ្នកពីរបៀបទ្រង់ចង់អោយអ្នករស់នៅ និង ឆ្លើយតបចំពោះស្ថានភាពនីមួយៗទាំងនេះ ។

កុំរងចាំ ហើយនិយាយថា " អូ! មិនអីទេ ខ្ញុំរៀបរយជីវិតរបស់ខ្ញុំនៅឆ្នាំក្រោយ, ខ្ញុំនឹងចាប់ផ្តើមបង្កើតគោលដៅខ្លះៗរបស់ខ្ញុំ ។ " កុំរងចាំ សូមចាប់ផ្តើមឥឡូវនេះ ហើយក៏មិនត្រូវរងចាំសំរាប់លក្ខខណ្ឌឥតខ្ចោះនោះទេ ។ ។ សាស្តា ១១:៤ ចែងថា " អ្នកដែលសំឡឹងមើលខ្យល់ មិនសាបព្រោះទេ ហើយអ្នកដែលតាមមើលពពកក៏មិនច្រូតកាត់ដែរ ។ នេះគឺជាអត្ថបទគម្ពីរខ្លះៗទៀតដែលបង្ហាញកិច្ចការខ្លះដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ ។

| | |
|---|---|
| ១ ពេត្រុស ១:៥-១១ | អេភេសូ ៦:១ |
| លូកា ៦:២៧-៣៨ | រ៉ូម ១៣:១-៥ |
| ១ កូរិនថូស ១៣:៤-៨ | ម៉ាកុស ១២:៣០-៣១ |

### ខ.    ប្រភេទគោលដៅផ្សេងៗគ្នា

មានប្រភេទគោលដៅផ្សេងៗគ្នាជាច្រើនដែលគ្រីស្តបរិស័ទអាចបង្កើតឡើង ។ នេះគឺជាកន្លែងផ្សេងៗគ្នាខ្លះៗដែលជាកន្លែងដែលអ្នកអាចបង្កើតគោលដៅបាន ។

១.    គោលដៅនៃការអប់រំ    ២.    គោលដៅការងារ    ៣.    គោលដៅខាងព្រលឹងវិញ្ញាណ

៤. គោលដៅនៃការអានព្រះគម្ពីរ និង ចងចាំព្រះគម្ពីរ ៥. គោលដៅចរិកលក្ខណៈ( ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន)

៦. គោលដៅអាកប្បកិរិយា ៧. ការអនុវត្តន៍អត្ថបទព្រះគម្ពីរនៅក្នុងជីវិត

៨. គោលដៅមិត្តភាព

## គ. តើអ្នកអាចចាប់ផ្តើមបង្កើតគោលដៅដោយរបៀបណា?

មានប្រភេទគោលដៅផ្សេងៗគ្នាជាច្រើនដែលអ្នកអាចបង្កើតដើម្បីជួយអ្នកអោយក្លាយទៅជាប្រកបដោយជ័យជំនះថែមទៀត ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតប្រភេទគោលដៅមួយអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង អ្នកដទៃ ។ អ្នកចាំបាច់ត្រូវតែរៀនពីរបៀបបង្កើតគោលដៅសំរាប់ការអនុវត្តន៍ផ្ទាល់ខ្លួន ។ ទាំងនេះគឺជាគោលដៅតូចៗដែលអ្នកអាចសំរេចវាបានក្នុងរយៈពេល ១ ថ្ងៃ ឬក៏ ពីរថ្ងៃ ។ វិធីមួយដើម្បីធ្វើអោយគោលដៅប្រចាំថ្ងៃទាំងនេះអាចអនុវត្តន៍គឺត្រូវពឹងផ្អែកទៅលើ ខ គម្ពីរនៅក្នុងព្រះគម្ពីរ ។

នៅពេលដែលអ្នករកឃើញ ខ គម្ពីរដែលនិយាយពីបញ្ហាដែលអ្នកកំពុងតែប្រឈមមុខ សូមសរសេរគោលដៅដែលនឹងជួយអ្នកអោយអនុវត្តន៍នូវអ្វីដែលខគម្ពីរនេះប្រាប់អ្នកអោយធ្វើ ។ នេះគឺជាការពន្យល់ពិស្តារថែមទៀតនៃវិធីមួយនៃការធ្វើកិច្ចការនេះ ។

### ១. មើលបញ្ហានៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក

អ្នកប្រហែលជាប្រឈមមុខជាមួយនឹងស្ថានភាពលំបាកៗខ្លះ ។ អ្នកមានអារម្មណ៍តាប់សង្កត់ ។ ប្រហែលជាអ្នកមិនដឹងនូវអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ ។ សូមមើលបញ្ហាទាំងនេះ និង សាកល្បងស្វែងរកអ្វីដែលកំពុងតែបង្កអោយមានបញ្ហាទាំងនេះ ។

### ២. សួរខ្លួនឯង "តើព្រះជាម្ចាស់កំពុងតែព្យាយាមបង្រៀនខ្ញុំឱ្យធ្វើអ្វីនៅថ្ងៃនេះក្នុងកន្លែងនេះនៃជីវិតរបស់ខ្ញុំ

អធិស្ឋាន និង សូមអោយព្រះជាម្ចាស់ជួយអ្នកយល់ដឹងនូវអ្វីដែលកំពុងតែបង្កបញ្ហា ។ សូមព្រះអង្គជួយអ្នកឱ្យមើលឃើញកន្លែងនៃជីវិតរបស់អ្នកដែលអ្នកចាំបាច់ត្រូវធ្វើអោយរីកចំរើន ធ្វើដូច្នេះអ្នកអាចយកជ័យជំនះលើបញ្ហានេះបាន ។

### ៣. រកឱ្យឃើញកន្លែងមួយនៃជីវិតរបស់អ្នកដែលអ្នកចង់រីកចំរើនថ្ងៃនេះ

ប្រសិនបើអ្នកលំបាកក្នុងការរកកន្លែងដែលអ្នកចង់អោយរីកចំរើន សូមពិនិត្យមើលបញ្ជីដែលត្រូវបានផ្តល់ជូននៅក្នុង ១ កូរិនថូស ១៣:៤-៨ ។

### ៤. ភ្ជាប់ការសិក្សាព្រះគម្ពីររបស់អ្នកចំពោះកន្លែងដែលអ្នកចង់រីកចំរើន

តើព្រះគម្ពីរចែងយ៉ាងដូចម្តេចអំពីកន្លែងនេះនៃជីវិតរបស់អ្នក? ស្វែងរកផ្នែកទាំងនោះនៅក្នុងព្រះគម្ពីរដែលនឹងជួយអ្នកអោយយល់ដឹងពីបញ្ហា និង ព្រះទ័យរបស់ព្រះជាម្ចាស់នៅលើការដោះស្រាយបញ្ហា ។ សូមស្វែងរកសេចក្តីសន្យា និង សេចក្តីពិតដែលអ្នកអាចអនុវត្តន៍នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក ។

### ៥. បង្ហាញកិច្ចការដែលអ្នកអាចបញ្ចប់ថ្ងៃនេះ

ឥឡូវនេះអ្នកបានសិក្សាព្រះគម្ពីរ សូមបង្ហាញគោលដៅអនុវត្តន៍ផ្ទាល់ខ្លួនជាច្រើនដែលអ្នកធ្វើទៅបាន ។ មុនដំបូង សូមចំណាយពេលវេលាដើម្បីរិះរកគំនិតថ្មីៗប្រកបដោយប្រាជ្ញាញាណ ។ បង្ហាញគំនិតដែលមានសក្តានុពលភាពជាគោលដៅ ។ បន្ទាប់មកជ្រើសរើសគោលដៅមួយសំរាប់ថ្ងៃនេះ ។ សូមប្រើការណែនាំដែលត្រូវបានបង្ហាញពេលក្រោយនៅក្នុងផ្នែកនេះ ដើម្បីរៀបចំគោលដៅប្រចាំថ្ងៃល្អៗ ។ បន្ទាប់មក ធ្វើអ្វីដែលអ្នកបានរៀបចំ ។ ធ្វើអ្វីដែលអ្នកមានគំរោងធ្វើ ។

## ៦. វាយតំលៃលទ្ធផល

ក្រោយមកនៅថ្ងៃដូចគ្នា ឬក៏ ថ្ងៃបន្ទាប់ មើលឡើងវិញនូវអ្វីដែលបានកើតឡើងនៅពេលអ្នកបានសាកល្បងសំរេចគោលដៅដែលអ្នកបានបង្កើតឡើង ។ ជួនកាល អ្នកនឹងមិនអាចសំរេចគោលដៅរបស់អ្នកបានទេ ។ ព្យាយាមម្តងទៀត កុំបោះបង់ចោល ។ កុំខ្លាចផ្លាស់ប្តូរគោលដៅរបស់អ្នក ។ ប៉ុន្តែផ្ទុយទៅវិញកុំផ្លាស់ប្តូរគោលដៅរបស់អ្នកដោយសារតែ អ្នកសាកល្បងលើកទីមួយ មិនបានទទួលជោគជ័យ ។

លោក ថូម៉ាស អីឌីសុន៍ (Thomas Edison) មិនបានទទួលជោគជ័យជាច្រើនដងមុននឹងគាត់បង្កើត អំពូលភ្លើងអោយមានដំណើរការនោះ ។ តាមពិតទៅ គាត់ទទួលបរាជ័យលើស ២000 ដងមុននឹងគាត់ទទួលជោគជ័យក្នុងការផលិតអំពូលភ្លើងឱ្យវាមានដំណើរការនោះ ។ កុំធ្វើជាអ្នកបោះបង់ចោល ឬក៏ លាចាកឈប់ធ្វើ ។ សូមមើល ២ កូរិនថូស ៨:១១ ។

នៅពេលដែលអ្នកមើលឡើងវិញនូវគំនិតទាំង ៦ ដែលត្រូវបានផ្តល់ជូននៅទីនេះ សូមកំណត់ចំណាំម្តងទៀតនូវចំនុចទី ១ " មើលបញ្ហានៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក " ។ យើងទាំងគ្នាភាគច្រើនមិនចូលចិត្តជំលោះនោះទេ ។ ប៉ុន្តែប្រសិនបើអ្នកចង់ក្លាយទៅជាគ្រិស្តបរិស័ទប្រកបទៅដោយជោគជ័យ នោះអ្នកត្រូវតែរៀនពីរបៀបប្រឈមមុខជំលោះ និង រីកចំរើនតាមរយៈបទពិសោធន៍ឈឺចាប់ទាំងនោះ ។ អ្នកត្រូវតែសុខចិត្តជួយដោះស្រាយបញ្ហាជំលោះ ។ វាងាយស្រួលណាស់ក្នុងការបន្ទាប់មនុស្សដទៃទៀត ហើយនិយាយថា " ខ្ញុំត្រូវ អ្នកខុស ។ " ព្រះជាម្ចាស់កំពុងស្វែងរកមនុស្សប្រុសស្រីដែលសុខចិត្តក្លាយជាអ្នកបង្កើតសន្តិភាព ។

ព្រះជាម្ចាស់មិនតំរូវអោយយើងត្រូវគ្រប់ពេលវេលានោះទេ--ភាពល្អឥតខ្ចោះនោះ ។ ព្រះជាម្ចាស់តំរូវអោយយើងស្មោះត្រង់ ។ នៅពេលដែលអ្នកខុស សូមសារភាព ។ ព្រះជាម្ចាស់នឹងនៅតែស្រលាញ់អ្នក ។ ទ្រង់នឹងជួយអ្នករៀនពីបទពិសោធន៍នោះ ប្រសិនបើអ្នកសុខចិត្តមករកទ្រង់ដោយមានចិត្តបើកចំហរ រៀបចំខ្លួនជាស្រេចដើម្បីរៀន ។ សូមមើល រ៉ូម ៥:៣-៥ ។

## ឃ. តើកំណត់សំគាល់គោលដៅប្រចាំថ្ងៃដ៏ល្អគឺជាអ្វី?

ដំបូងការរៀនសរសេរគោលដៅល្អៗប្រចាំថ្ងៃគឺជារឿយៗពិបាក ។ យើងភាគច្រើនមិនដែលបានធ្វើកិច្ចការនេះពីមុនមកនោះទេ ។ ជាមួយនឹងជំនាញថ្មីខ្លះ ការអនុវត្តន៍ធ្វើអោយល្អឥតខ្ចោះ ។ អ្នកសរសេរគោលដៅកាន់តែច្រើន អ្នកនឹងកាន់តែប្រសើរខាងធ្វើកិច្ចការនេះ និង មានប្រយោជន៍កាន់តែច្រើនសំរាប់ការរីកចំរើនខាងជីវិតគ្រិស្តបរិស័ទរបស់អ្នក ។ នេះគឺជាសេចក្តីណែនាំខ្លះៗដែលអាចជួយអ្នករៀនពីរបៀបធ្វើអោយប្រសើរនៃគោលដៅប្រចាំថ្ងៃរបស់អ្នក ។

១. **ងាយស្រួល.** វានិយាយតែកិច្ចការមួយប៉ុណ្ណោះ ។ វាគ្មានការសង្ស័យនៅក្នុងចិត្តគំនិតរបស់អ្នកនូវអ្វីដែលអ្នកដែលប៉ងចង់បំពេញ ។

២. **ច្បាស់លាស់.** វាបញ្ជាក់យ៉ាងច្បាស់នូវចំនុច ។ មានពេលវេលាជាច្រើនគោលដៅរបស់យើងទូទៅពេក ។ សូមឱ្យយើងមើលគោលដៅនេះ " ខ្ញុំនឹងចូលទៅជិតព្រះជាម្ចាស់ " ។ គោលដៅនេះទូទៅពេក ។ តើអ្នកនឹងចូលទៅជិតព្រះជាម្ចាស់ដោយរបៀបណា? វានឹងល្អជាងក្នុងការសំរេចចិត្តនៅលើកិច្ចការជាក់លាក់មួយដែលអ្នកអាចធ្វើ ដែលនឹងប្រាកដជានាំអ្នកចូលទៅជិតព្រះជាម្ចាស់ ។ បង្កើតគោលដៅនោះគឺជាគោលដៅទីមួយរបស់អ្នក ។ នៅពេលដែលអ្នកសំរេចគោលដៅនោះ បង្កើតគោលដៅមួយទៀតដែលនឹងពង្រឹងគោលដៅទី ១ វាដូចជាជួយអ្នកអោយឈានមួយជំហានទៀតនៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ ។ ត្រូវតែចំទិសដៅ និង ច្បាស់លាស់នៅក្នុងពាក្យនៃគោលដៅនីមួយៗ ។ សូមកុំអោយមានភាពស្មុគស្មាញដោយកំណត់តែមួយសកម្មភាព ។

៣. **មានអត្ថន័យ.** វាទាក់ទងទៅនឹងជីវិតរបស់ខ្ញុំថ្ងៃនេះ ។ គោលដៅ " ប្រសិនបើខ្ញុំមាន ខ្ញុំនឹងថ្វាយ ៥0 ដុល្លាដល់ក្រុមជំនុំរបស់ខ្ញុំរាល់ថ្ងៃអាទិត្យ ។ " មិនមានប្រយោជន៍នោះទេ លុះត្រាតែអ្នកមានរួចទៅហើយ ។ នៅពេលដែលអ្នកមាន នោះបង្កើតគោលដៅទាក់ទងជាមួយនឹងទ្រព្យសម្បត្តិរបស់អ្នក ។ គោលដៅរបស់អ្នកត្រូវតែចេញពីអ្វីដែលអ្នកដឹងថាវាអាចទៅរួចនៅក្នុងជីវិតសព្វថ្ងៃរបស់អ្នក ។ វាត្រូវតែនាំទៅរកការផ្លាស់ប្តូរផងដែរ ថាអ្នកពិតជាចង់ឃើញវាកើតឡើង ។

៤. **អនុវត្តន៍បាន.** តើអ្នកអាចបញ្ចប់វាថ្ងៃនេះដែរឬទេ? គោលដៅ "រាល់ពេលដែលខ្ញុំជួបល្បួងខ្ញុំនឹងដឹងថាវាគឺជាអារក្សសាតាំងកំពុងតែល្បួងខ្ញុំ " ស្តាប់គោលដៅនេះទៅល្អណាស់ ប៉ុន្តែតើវាគួរអោយអនុវត្តន៏បានឬទេ? តើអ្នកនឹងចង់ចាំប្រាប់ខ្លួនអ្នកផ្ទាល់ថាការល្បួងមកពីអារក្សសាតាំងរាល់ពេលវេលាអ្នកជួបការល្បួង? " គោលដៅនោះមើលទៅវាទាក់ទៅនឹងព្រលឹងវិញ្ញាណ ប៉ុន្តែវាធំពេកសំរាប់ការប៉ុនប៉ងដំបូងរបស់គ្រីស្ទបរិស័ទថ្មីក្នុងការយកជ័យជំនះលើការល្បួង ។

ចាប់ផ្តើមជាមួយនឹងគោលដៅខ្លី និង សាមញ្ញដែលអអ្នកប្រាកដថា អ្នកអាចបំពេញនៅក្នុងមួយថ្ងៃ ។ យកគោលដៅនេះជាឧទាហរណ៍ " ថ្ងៃនេះ ខ្ញុំនឹងធ្វើបញ្ជីរាល់ពេលដែលខ្ញុំជួបការល្បួងអោយធ្វើអំពើបាប ។ " អ្នកអាចធ្វើអោយគោលដៅនេះកាន់តែជាក់លាក់ថែមទៀតដោយបង្ហាញគ្រាន់តែមួយប្រភេទនៃការល្បួង ឧទាហរណ៏ " នៅពេលជួបការល្បួងអោយដាក់បណ្តាសារ ។ "

៥. **អាចត្រូវបានវាស់វែងបាន.** តើអ្នកនឹងវាស់វែងគោលដៅនេះដោយរបៀបណា? " ថ្ងៃនេះ ខ្ញុំនឹងចូលទៅជិតព្រះជាម្ចាស់ ។ " គោលដៅនេះមិនត្រូវបានសរសេរនៅក្នុងវិធីមួយអោយមានការងាយស្រួលក្នុងវាស់វែងនោះទេ ។ ប្រសិនបើអ្នកចង់ប្រាកដថា អ្នកនឹងរីកចំរើនឡើង អ្នកចាំបាច់ត្រូវតែសរសេរគោលដៅរបស់អ្នកនៅក្នុងវិធីមួយដែលអ្នកអាចវាស់វែងភាពរីកចំរើនរបស់អ្នកយ៉ាងងាយស្រួល ។ គោលដៅ " ថ្ងៃនេះ ខ្ញុំនឹងធ្វើបញ្ជីរាល់ពេល ខ្ញុំជួបការល្បួងអោយធ្វើអំពើបាប" អាចត្រូវបានវាស់វែងបាន ។ នៅពេលអ្នកធ្វើបញ្ជី អ្នកបំពេញសកម្មភាពដែលអាចត្រូវបានវាស់វែងបាន ។

វាពិបាកក្នុងការសរសេរគោលដៅដែលអាចវាស់វែងបានយ៉ាងងាយស្រួលនោះ ។ ប៉ុន្តែ វាសំខាន់ ប្រសិនបើអ្នកចង់ប្រាកដថា អ្នកនឹងមានការរីកចំរើន ។ នេះគឺជាសំនួរ ៤ ដែលអ្នកអាចសួរខ្លួនឯងផ្ទាល់ នៅពេលដែលអ្នកសរសេរគោលដៅរបស់អ្នក ។

**តើ**គេនឹងវាស់អ្វី?

តើ**ឧបករណ៍**អ្វីនឹងត្រូវបានគេប្រើដើម្បីវាស់?

តើវា**ងាយស្រួល**វាស់ទេ?

តើការរីកចំរើនរបស់ខ្ញុំអាចត្រូវបានវាស់ដោយមនុស្សដទៃ**ដោយរបៀបណា**?

គោលដៅទាំងនេះគឺជាសាមញ្ញ និង អាចវាស់វែងបាន ។ " យប់នេះ ខ្ញុំនឹងសរសេរចូលការល្បួង ៣ យ៉ាងដែលខ្ញុំបានពិសោធន៍ថ្ងៃនេះ ។ " " ខ្ញុំនឹងសួរ ប៉ែតអោយអត់ទោសអោយខ្ញុំកាលដែលខ្ញុំខឹងដាក់គាត់កាលពីម្សិលមិញ ។ "

**៦. ខាជួយខ្ញុំ.** គោលបំណងទាំងមូលនៃការអនុវត្តន៏គោលដៅផ្ទាល់ខ្លួនរបស់ខ្ញុំគឺជួយអោយខ្ញុំចូលទៅជិតព្រះជាម្ចាស់ ។ គិតនៅខាងមុខ។ នៅពេលដែលអ្នកសរសេរគោលដៅរបស់អ្នក សូមសួរខ្លួនឯងផ្ទាល់ " តើគោលដៅនេះនឹងជួយខ្ញុំអោយរីកចំរើនបានដោយរបៀបណា? " នៅពេលដែលអ្នកធ្វើការបំពេញគោលដៅនីមួយៗ តើអ្នកអាចមើលឃើញពីរបៀបការនេះនឹងជួយអ្នកអោយក្លាយជាគ្រីស្ទបរិស័ទប្រសើរឬទេ?

ការណែនាំទាំង ៦ យ៉ាងនេះនឹងមិនធានាជោគជ័យសំរាប់អ្នកនោះទេ ។ ការសរសេរគោលដៅអនុវត្តន៏ផ្ទាល់ដ៏ល្អមិនធ្វើឱ្យអ្នកក្លាយជាគ្រីស្ទបរិស័ទប្រកបទៅដោយជោគជ័យដោយស្វ័យប្រវត្តន៏នោះទេ ។ តាមពិតទៅ គោលដៅគឺជាឧបករណ៍ប៉ុណ្ណោះ--ដើម្បីធ្វើអោយអ្នករីកចំរើន ។ ព្រះជាម្ចាស់យកព្រះទ័យទុកដាក់បំផុតអំពីការរីកចំរើនរបស់យើង មិនមែន " តើអ្នកបានសរសេរគោលដៅដ៏ល្អឬទេ? " ប៉ុន្តែ ប្រសិនបើអ្នករៀនពីរបៀបសរសេរគោលដៅដ៏ល្អនោះ ហើយអ្នកស្មោះត្រង់ក្នុងការអនុវត្តន៏គោលដៅទាំងនេះ ព្រះជាម្ចាស់នឹងជួយអោយអ្នករីកចំរើន និង ក្លាយទៅជាមនុស្សដែលទ្រង់ចង់អោយអ្នកក្លាយទៅជា ។ ព្រះជាម្ចាស់មិនសង្ឃឹមអ្វីៗដែលល្អឥតខ្ចោះពីអ្នកនោះទេ ប៉ុន្តែ ព្រះជាម្ចាស់ពិតជារំពឹងឱ្យអ្នកអនុវត្តន៏ការបង្រៀនរបស់ទ្រង់ចំពោះជីវិតរបស់អ្នក ។

នៅពេលដែលអ្នកមើលពីអនាគត តើអ្នកឃើញអ្វី? តើមនុស្សប្រភេទណាដែលអ្នកចង់ប្រដូចទៅនឹងក្នុងរយៈពេល ២ ឆ្នាំ ចាប់ពីពេលនេះតទៅ? . . . ៥ ឆ្នាំ ចាប់ពីពេលនេះតទៅ? . . . ១០ ឆ្នាំ ចាប់ពីពេលនេះតទៅ? ព្រះជាម្ចាស់ផ្តល់តំលៃដល់គ្រីស្ទបរិស័ទដែលធ្វើការប្តេជ្ញាចិត្តស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់ ។ តើអ្នកអាចបង្ហាញខ្លួនអ្នកផ្ទាល់ក្នុងរយៈពេល ១០ ឆ្នាំចាប់ពីពេលនេះតទៅជានរណាម្នាក់ដែលបានរស់នៅយ៉ាងស្មោះត្រង់សំរាប់ព្រះគ្រីស្ទ? តើអ្នកអាចមើលឃើញខ្លួនអ្នកផ្ទាល់ជានរណាម្នាក់ដែលបានផ្តល់អាទិភាពខ្ពស់ក្នុងការស្តាប់បង្គាប់វិន័យ និង ការបង្រៀនរបស់ព្រះគម្ពីរ?

បញ្ហាមួយទៀតដែលប្រឈមមុខអ្នកនៅក្នុងជីវិតរបស់អ្នកគឺ ត្រូវបង្កើតអោយមានស្ថេរភាពក្នុងជីវិត ។ តើអ្នកជាមនុស្សមួយប្រភេទដែលនឹងត្រូវប្រឈមមុខនឹងកូលីយ៉ាតនៅថ្ងៃនេះ ប៉ុន្តែមានការភ័យខ្លាចពីស្រមោលខ្លួនឯងសំរាប់ថ្ងៃស្អែក? តើអ្នកជាមនុស្សប្រភេទដែលស្ថិតនៅក្នុងជ្រលងនៃការថប់បារម្ភ ហើយថ្ងៃបន្ទាប់ទៀតមានការធ្លាក់ទឹកចិត្តដែររឺទេ? ព្រះជាម្ចាស់កសាងស្ថេរភាពនៅក្នុងជីវិតរបស់អ្នកបាន ។ អ្នកនឹងបន្តមានថ្ងៃដែលល្អ ហើយក៏នៅតែថ្ងៃអាក្រក់ផងដែរ ។ ប៉ុន្តែតាមរយៈការទាំងនោះ អ្នកអាចរៀនពីរបៀបក្នុងការទុកចិត្តលើព្រះយេស៊ូ ហើយមិនមែនអនុញ្ញាតអោយបញ្ហាចូលមកគ្រប់គ្រងក្នុងជីវិតរបស់អ្នកបានឡើយ ។ គ្មានការព្យាបាលបែបមន្តអាគមន៏ណារងចាំសំរាប់មនុស្សអោយទទួលបាននូវស្ថេរភាពបានឡើយ ។ វាត្រូវការប្រើរយៈពេលយូរ ហើយខិតខំធ្វើការជាខ្លាំង និង បន្តដាក់ភ្នែករបស់អ្នកលើព្រះយេស៊ូគ្រីស្ទ និងសេចក្តីបង្រៀនរបស់ទ្រង់ ។

## ជំហាន ទី ៤. រៀនរបៀបរៀបចំអារម្មណ៍របស់អ្នក

អ្នកមិនមែនជាគ្រីស្តបរិស័ទគ្រាន់តែអ្នកមានអារម្មណ៍ថា " បានសង្គ្រោះនោះទេ " ទោះបីជាអារម្មណ៍យ៉ាងម៉េចក៏ដោយក៏អ្នកមិនអាចជាគ្រីស្តបរិស័ទបានដែរ ។ ប៉ុន្តែ អារម្មណ៍របស់អ្នកគឺជាផ្នែកមួយយ៉ាងសំខាន់នៃការរស់នៅប្រចាំថ្ងៃរបស់អ្នក ។ ព្រះជាម្ចាស់បានផ្តល់អារម្មណ៍ទាំងនោះដល់អ្នក ឥឡូវនេះ អ្នកត្រូវតែរៀនពីរបៀបប្រើអារម្មណ៍របស់អ្នកនៅក្នុងវិធីមួយដែលធ្វើអោយជីវិតរបស់អ្នកមានអំណរ នង គាប់ព្រះទ័យព្រះជាម្ចាស់ ។ ព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងច្រើនអំពីអារម្មណ៍ផ្សេងៗគ្នានៅក្នុងព្រះគម្ពីរ ។ អ្នកចាំបាច់ត្រូវតែរកអោយឃើញពីរបៀបអារម្មណ៍របស់អ្នកអាចជួយអោយអ្នកក្លាយជាគ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យថែមទៀត ។

ជំហានជាមូលដ្ឋានសំខាន់បំផុតមួយនៅក្នុងចំណោមជំហានជាច្រើននៃការរីកចំរើននៅក្នុងកន្លែងនេះនៃជីវិតរបស់អ្នកគឺត្រូវនៅជាប់ជាមួយនឹងអារម្មណ៍របស់អ្នក ។ រៀនកត់សំគាល់របៀបណា ឬពេលណាអ្នកបង្ហាញអារម្មណ៍ផ្សេងៗ ។ ទទួលយក និង រៀនបង្ហាញអារម្មណ៍ទាំងនោះ ។ កុំអនុញ្ញាត្តអោយអារម្មណ៍របស់អ្នកគ្រប់គ្រងលើជីវិតរបស់អ្នកទាំងមូល ។ អារម្មណ៍របស់អ្នកយ៉ាងណានោះ គួរតែមិនមែនជាកត្តាសំខាន់នៅក្នុងការធ្វើការសំរេចដែលអ្នកបានធ្វើ ។

ព្រះជាម្ចាស់ចង់អោយអ្នកពិសោធន៍អំណរក្នុងការរស់នៅជាមួយនឹងទ្រង់ ។ ព្រះអង្គអាចជួយអ្នកអោយរកឃើញនូវផ្លូវប្រកប ទៅដោយការឆ្លៃប្រឌិតនៃការបង្ហាញអារម្មណ៍របស់អ្នក។ អ្នកអាចពិសោធន៍អំណរនៃការសង្គ្រោះរបស់ទ្រង់ ។ អ្នកប្រហែល ជាចង់សិក្សាសញ្ញាថ្មីដើម្បីអោយមើលឃើញពីរបៀបព្រះយេស៊ូបង្ហាញអារម្មណ៍ផ្សេងៗគ្នាជាច្រើន ។ ព្រះជាម្ចាស់ ចង់អោយ អ្នករីកចំរើនដល់កន្លែងដែលអ្នកអាចគ្រប់គ្រងអារម្មណ៍របស់អ្នក និង អ្នកបង្ហាញអារម្មណ៍ ទាំងនោះនៅក្នុងវិធីមួយដែល មនុស្សអាចមើលឃើញ ទ្រង់គឺជាអ្នកដឹកនាំនៃជីវិតរបស់អ្នក ។

ការគ្រប់គ្រងអារម្មណ៍របស់អ្នកមិនមែនមានន័យគ្រាន់តែមិននិយាយវាចេញមកបានហើយនោះទេ ។ ប្រហែលវាប្រសើរជាងក្នុងការនិយាយចេញមក អ្នកចាំបាច់ត្រូវតែរៀនពីរបៀបគ្រប់គ្រប់អារម្មណ៍របស់អ្នក ។ ព្រះជាម្ចាស់ចង់អោយអ្នកក្លាយទៅជាមនុស្សមួយដែលមានអារម្មណ៍ ។ ចំនុចសំខាន់គឺរៀនបង្ហាញអារម្មណ៍ទាំងនោះនៅក្នុងផ្លូវមួយដែលនឹងនាំសេរីល្អដល់ព្រះជាម្ចាស់ ។

### ក. អ្នករៀនគ្រប់គ្រងអារម្មណ៍របស់អ្នកដោយបង្កើតអាកប្បកិរិយាដែលមានមូលដ្ឋាននៅលើអត្ថបទព្រះគម្ពីរ

នៅក្នុងជំហាន ទី ២ យើងបានពិភាក្សាភាពផ្សេងៗគ្នារវាងអាកប្បកិរិយា និង អារម្មណ៍ ។ អាកប្បកិរិយា អ្នកមានចំពោះមនុស្សពិសេសណាម្នាក់ ឬក៏ ស្ថានភាពនឹងកំណត់ពីរបៀបអ្នកឆ្លើយតបជាមួយអារម្មណ៍របស់អ្នក ។ នៅក្នុងករណីជាច្រើន អារម្មណ៍របស់អ្នកគឺជាសភាពខាងក្រៅនៃអាក្សបកិរិយារបស់អ្នកក្នុងស្ថានភាពមួយដ៏ជាក់លាក់ ។

ប្រសិនបើអ្នកចង់ផ្លាស់ប្តូរវិធីដែលអ្នកបង្ហាញអារម្មណ៍របស់អ្នក ដំបូងអ្នកត្រូវតែបង្កើតអាកប្បកិរិយាថ្មីដែលមានមូលដ្ឋាននៅលើការបង្រៀនរបស់ព្រះគម្ពីរ ។ ម៉ាកុស ៣:១-៨ ប្រាប់ពេលវេលានៅពេលព្រះគ្រីស្តទ្រង់ខ្ញាល់ ។ តើគំនិតអ្វីដែលមាននៅក្នុងចិត្តគំនិតរបស់ព្រះគ្រីស្ត នៅពេលទ្រង់មានអារម្មណ៍ខ្ញាល់? តើទ្រង់បង្ហាញកំហឹងរបស់ទ្រង់ដោយរបៀបណា? ចំលើយចំពោះសំនួរទាំងនេះនឹងបង្ហាញអាកប្បកិរិយារបស់ទ្រង់ចំពោះសកម្មភាពនោះ ។

## ខ. នៅពេលដែលអ្នកមានអារម្មណ៍ " ខុសឆ្គង " អោយអារម្មណ៍នោះចេញតាមរយៈការអធិស្ឋានដល់ព្រះអង្គ

អារម្មណ៏មានទាំងល្អ និង អាក្រក់ ។ ពួកគេ "អព្យាក្រិត " ព្រះជាម្ចាស់បង្កើតយើងមកជាមួយនឹងលទ្ធភាពពិសោធន៏នឹងអារម្មណ៏ផ្សេងៗគ្នាជាច្រើន ។ ចុះអារម្មណ៏ខុសឆ្គងយ៉ាងដូចម្តេចដែរ? នៅពេលដែលអារម្មណ៏ណាមួយត្រូវបានបង្ហាញនៅពេលវេលាមិនល្អ ឬក៏ នៅក្នុងវិធីមិនត្រឹមត្រូវ វាគឺជាអារម្មណ៏ ខុសឆ្គង ។ ឧទាហរណ៏ មិត្តរួមថ្នាក់របស់ ប៊ិលទើបតែបានឮដំណឹងមកពីផ្ទះថា គេបានសម្លាប់ឪពុកម្តាយរបស់គាត់ ។ ប្រសិនបើ ប៊ិលផ្ទុះសំណើច នោះគឺជាពេលវេលា និងកន្លែងមិនត្រឹមត្រូវនោះទេក្នុងការបង្ហាញអារម្មណ៏សប្បាយនោះ ។

តើអ្នកគួរតែធ្វើយ៉ាងដូចម្តេច នៅពេលដែលអ្នកមានអារម្មណ៏ចង់បង្ហាញអារម្មណ៏នៅពេលវេលាមិនត្រឹមត្រូវ? កុំយកវាមកធ្វើជាទម្លាប់ទប់ ឬក៏ ទុកវានៅក្នុងចិត្ត ។ រៀនពីរបៀបបញ្ចេញអារម្មណ៏នេះដល់ព្រះជាម្ចាស់តាមរយៈការអធិស្ឋានប្រាប់ដល់ព្រះជាម្ចាស់ត្រង់ៗនូវអារម្មណ៏របស់អ្នក ។ នៅពេលដែលអ្នកប្រាប់ទ្រង់នូវអារម្មណ៏របស់អ្នក កិច្ចការនេះអាចផ្តល់អោយអ្នកនូវការបញ្ចេញជាបណ្តោះអាសន្នសំរាប់អារម្មណ៏នេះ ។

ដំណោះស្រាយជាអចិន្ត្រៃ ឬក៏ យូរអង្វែងចំពោះ " អារម្មណ៏ខុសឆ្គង " សូមមើលនូវអាកប្បកិរិយារបស់អ្នក ។ អ្នកប្រហែលជាចាំបាច់ត្រូវផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកចំពោះនរណា ឬក៏ អ្វីដែលបានបណ្តាលអ្នកចង់ឆ្លើយតបជាមួយនឹង " អារម្មណ៏ខុសឆ្គង ។ "

យើងទាំងអស់គ្នាពិសោធន៏អារម្មណ៏ដូចជាសំអប់, កំហឹង, ឬក៏ សេចក្តីភ័យខ្លាចនៅពេលវេលាខុសៗគ្នានៅក្នុងជីវិតរបស់យើង ។ ប្រហែលជាគំរូចាស់នៃការឆ្លើយតបរបស់អ្នកគឺអនុញ្ញាត្តអោយអារម្មណ៏ទាំងនេះគ្រប់គ្រងគំនិត, ពាក្យសំដី និងសកម្មភាពរបស់អ្នក ។ ប៉ុន្តែឥឡូវនេះ អ្នកបានក្លាយទៅជាគ្រីស្តបរិស័ទ អ្នកប្រហែលជាចង់ផ្លាស់ប្តូរ និង បង្កើតឡើងនូវគំរូថ្មីខ្លះៗនៃការឆ្លើយតប ។ " ប៉ុន្តែតើខ្ញុំគួរតែធ្វើអ្វីនៅពេលដែលអារម្មណ៏ខុសឆ្គងទាំងកើតមានឡើង? " ជាមួយនឹងជំនួយរបស់ព្រះជាម្ចាស់ អ្នកអាចអនុញ្ញាត្តអោយទ្រង់យកនូវអារម្មណ៏ទាំងនេះចេញ និង ជំនួសមកវិញនូវអារម្មណ៏ដ៏សមរម្យជាងសំរាប់ស្ថានភាពនោះ ។ ឧទាហរណ៏ មានពេលជាច្រើនដងនៅពេលដែលយើងមានប្រតិកម្មជាមួយនឹងកំហឹង ព្រះជាម្ចាស់ចង់អោយយើងមានប្រតិកម្មជាមួយនឹងទុក្ខព្រួយវិញ ។

គោលបំណងដ៏ខ្ពស់របស់អ្នកគួរតែឆ្លើយតបខាងអារម្មណ៏ទៅតាមផ្លូវដែលព្រះជាម្ចាស់ចង់អោយអ្នកឆ្លើយតប ។ គោលបំណងដទៃទៀតគឺត្រូវរៀនចាប់អារម្មណ៏ផ្លូវដែលព្រះជាម្ចាស់ចាប់អារម្មណ៏នៅក្នុងគ្រប់ស្ថានភាព ។ ... នៅពេលដែលអ្នកសិក្សាព្រះគម្ពីរ និង អធិស្ឋាន ព្រះជាម្ចាស់នឹងជួយអ្នកអោយរៀនពីរបៀបព្រះជាម្ចាស់មានព្រះទ័យយ៉ាងដូចម្តេចអំពីកិច្ចការដែលអ្នកប្រឈមមុខនៅក្នុងជីវិត ។ ទ្រង់នឹងផ្តល់អោយអ្នកនូវអំណាចដើម្បីឆ្លើយតបវិធីដូចគ្នា ។

ព្រះគម្ពីរបង្រៀនថា អ្នកគួរតែជាម្ចាស់នៃអារម្មណ៏របស់អ្នក ។ កុំអនុញ្ញាត្តអោយមនុស្ស ឬក៏ បញ្ហាគ្រប់គ្រងអារម្មណ៏របស់អ្នក ។

វាត្រូវការពេលវេលាដើម្បីរៀនពីរបៀបគ្រប់គ្រងអារម្មណ៏របស់អ្នកនៅក្នុងផ្លូវដែលព្រះជាម្ចាស់ចង់ ។ ក្នុងនាមជាគ្រីស្តបរិស័ទកំពុងតែរីកចំរើន កុំអនុញ្ញាត្តអោយអារម្មណ៏អវិជ្ជមាន ឬក៏ ការខ្វះខាងផ្លូវព្រះវិញ្ញាណធ្វើអោយអ្នកមិនសប្បាយចិត្តឡើយ ។ អារម្មណ៏សំខាន់បំផុតខ្លះៗដែលគួរតែមានវត្តមាននៅក្នុងជីវិតគ្រីស្តបរិស័ទគឺសេចក្តីស្រលាញ់, សេចក្តីសុខសាន្ត,

និង អំណរ ។ អារម្មណ៍ទាំង ៣ នេះប្រហែលជាមិនតែងតែមានវត្តមាននៅក្នុងជីវិតអ្នកនោះទេ ប៉ុន្តែអារម្មណ៍ទាំងនេះគួរតែរីកចំរើនកាន់តែខ្លាំងៗរាល់ថ្ងៃនៅក្នុងជីវិតរបស់អ្នក ។

### គ. រៀនឆាប់យល់ចំពោះអារម្មណ៍នៃមនុស្សដទៃទៀត

វាងាយស្រួលក្នុងការក្លាយជាមនុស្សអាត្មានិយម ហើយគិតតែពីខ្លួនឯង ។ ប៉ុន្តែព្រះយេស៊ូចង់អោយយើងគិតអំពីអ្នកដទៃ និង ឆាប់យល់ដឹងចំពោះអារម្មណ៍របស់ពួកគេ ។ ១ កូរិនថូស ១០:២៩ ចែងថា " ខ្ញុំមិននិយាយអំពីមនសិការរបស់បងប្អូនទេ គឺសំដៅទៅលើមនសិការរបស់អ្នកដែលបានប្រាប់បងប្អូននោះវិញ ។ ហេតុអ្វីបានជាសេរីភាពរបស់ខ្ញុំក្នុងការប្រព្រឹត្តិបែរជាត្រូវសំរបទៅតាមមនសិការរបស់អ្នកដទៃដូច្នេះ? "

អាកប្បកិរិយាដែលមានតំលៃមួយដើម្បីបង្កើតឡើងគឺសួរខ្លួនឯងនូវសំនួរនេះ " តើអារម្មណ៍អ្វីដែលព្រះជាម្ចាស់មានចំពោះខ្ញុំ និង ចំពោះមនុស្សដទៃទៀតដែលខ្ញុំជួបរាល់ថ្ងៃ? " ព្យាយាមឆាប់យល់ដឹងអារម្មណ៍របស់ព្រះជាម្ចាស់ ។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះជាម្ចាស់រៀបចំរួចជាស្រេចដើម្បីអត់ទោសអោយយើងនៅដែលយើងបរាជ័យ ។ យើងត្រូវតែរៀនរស់នៅជាមួយនឹងអាកប្បកិរិយា " ចេះអត់ទោសតាមពេលវេលា " ។ អ្នកប្រហែលជាជួបការល្បួងដោយខឹងនឹងអ្នកដទៃដែលធ្វើអោយអ្នកអាក់អន់ចិត្ត ។ ដូច្នេះត្រូវតែរៀបចំខ្លួនរួចជាស្រេចដើម្បីអត់ទោសឱ្យពួកគេ ហើយកុំគំគួនជាមួយពួកគេ ។

អ្នកត្រូវតែទទួលយកការអត់ទោសរបស់ព្រះជាម្ចាស់ផងដែរនៅពេលដែលអ្នកធ្លាក់ ។ កុំអនុញ្ញាតអោយអារម្មណ៍ធ្លាក់ទឹកចិត្តធ្វើអោយអ្នកឃ្លាតឆ្ងាយពីការចូលមកជិតព្រះជាម្ចាស់អោយសោះបន្ទាប់ពីអ្នកបរាជ័យ ។ ព្រះជាម្ចាស់នឹងជួយអ្នកអោយរីកចំរើន ទោះបីជាអ្នកមានអារម្មណ៍ថាដូចជាបរាជ័យក៏ដោយ ។ សេចក្តីសន្យានៅក្នុង ភីលីព ៤:១៣គឺពិតប្រាកដសំរាប់អ្នក ។ " ខ្ញុំអាចទ្រាំទ្របានទាំងអស់ដោយរួមជាមួយព្រះអង្គដែលប្រទានកំឡាំងអោយខ្ញុំ ។ " ព្រះជាម្ចាស់នឹងផ្តល់ឱ្យអ្នកនូវកំឡាំងខាងស្មារតីដែលអ្នកត្រូវការដើម្បីប្រឈមមុខការលំបាករាល់ថ្ងៃ ។ ព្រះអង្គក៏អាចផ្តល់ផងដែរដល់អ្នកនូវកំលាំង និង ការឆាប់យល់ដឹងខាងវិញ្ញាណដើម្បីអោយមើលឃើញពីរបៀបដែលមនុស្សដទៃយល់ដឹងអំពីស្ថានភាពនេះ ។

## ជំហាន ទី ៥ : ចែកចាយជាមួយអ្នកដទៃនូវអ្វីដែលព្រះគ្រីស្ទបានធ្វើនៅក្នុងជីវិតរបស់អ្នក

វាសំខាន់ណាស់ដើម្បីអនុវត្តជំហានទាំង ៤ ដំបូងគេដើម្បីឱ្យអ្នកក្លាយទៅជាគ្រីស្តបរិស័ទប្រកបទៅដោយជ័យជំនះ ។ ប្រសិនបើអ្នកកំពុងតែអនុវត្តនៅជំហានទាំង ៤ នេះ អ្នកប្រហែលជាចង់ចែកចាយជាមួយអ្នកដទៃនូវអ្វីដែលព្រះគ្រីស្តកំពុងតែធ្វើនៅក្នុងជីវិតរបស់អ្នក ។

ប្រសិនបើអ្នកកំពុងតែរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទប្រកបទៅដោយជ័យជំនះ អ្នកដទៃនឹងចង់ដឹងពីរបៀបអ្នកធ្វើកិច្ចការនេះ ។ នេះគឺជាឱកាសដ៏អស្ចារ្យមួយសំរាប់អ្នកដើម្បីបង្ហាញពួកគេដល់ព្រះវិញ្ញាណដ៏វិសុទ្ធដែលបានបានធ្វើការផ្លាស់ប្តូរពិតប្រាកដដល់ជីវិតមនុស្ស ។ គោលដៅថ្មីមួយរបស់អ្នកគួរតែចែកចាយជាមួយអ្នកដទៃនៃអ្វីដែលព្រះគ្រីស្តកំពុងតែធ្វើនៅក្នុងជីវិតរបស់អ្នក ។ តើវិធីដ៏ល្អបំផុតដើម្បីធ្វើកិច្ចការនេះគឺជាអ្វី?

### ក. ជាដំបូងចែកចាយសេចក្តីស្រលាញ់របស់អ្នក

១ កូរិនថូស ១៣:១-៨ ប្រាប់យើងពីសារៈសំខាន់នៃសេចក្តីស្រលាញ់ និង ពីរបៀបយើងអាចបង្ហាញសេចក្តីស្រលាញ់ដល់អ្នកដទៃទៀត ។ កិច្ចការការទាំងនេះងាយស្រួលណាស់ ហើយក៏ ជាវិធីមួយដ៏សាមញ្ញក្នុងការចែកចាយសេចក្តីស្រលាញ់ជាមួយអ្នកដទៃទៀត ។ ( មនុស្សមិនងាយស្រួលទេ! ) ។ សេចក្តីស្រលាញ់គឺជាកំលាំងដ៏មានអំណាចបំផុតមួយនៅ

ក្នុងពិភពលោកយើងនេះ ។ សេចក្ដីស្រលាញ់របស់អ្នកនឹងធ្វើអោយមនុស្សដទៃទៀតជឿថាការក្លាយជាគ្រីស្ទបរិស័ទគឺជាកិច្ចការដ៏ល្អមួយគ្មានអ្វីផ្សេងទៀតក្រៅពីសេចក្ដីស្រលាញ់របស់អ្នកនោះទេ ។

### ខ. ស្វែងរកមនុស្សដែលមានតំរូវការពិតប្រាកដ

មនុស្សជារឿយៗតែងតែបើកចំហរចំពោះគំនិតថ្មី នៅពេលដែលពួកគេមានបញ្ហាដែលពួកគេមិនអាចដោះស្រាយបានដោយខ្លួនឯង ។ មានពេលជាច្រើន មនុស្សនៅក្នុងស្ថានភាពនេះនឹងចាប់អារម្មណ៍ពីរបៀបព្រះយេស៊ូអាចជួយគាត់ជាមួយនឹងបញ្ហារបស់គាត់ ។ សូមព្រះវិញ្ញាណដ៏បរិសុទ្ធដឹកនាំអ្នកទៅកាន់មនុស្សដែលមានតំរូវការ ។

### គ. ស្វែងរកមនុស្សដែលចង់បានជំនួយ

មានមនុស្សជាច្រើនដែលមានតំរូវការពិតប្រាកដ ។ ប៉ុន្តែមិនមែនមនុស្សទាំងអស់គ្នានោះទេដែលចង់បានជំនួយ ។ កុំបង្ខំមនុស្សអោយស្ដាប់អ្នកអោយសោះ ។ ប្រសិនបើពួកគេមិនចង់បានជំនួយ នោះមានការតិចតួចណាស់ដែលអ្នកអាចធ្វើសំរាប់ពួកគេលើកលែងតែរក្សានូវការបង្ហាញសេចក្ដីស្រលាញ់ចំពោះពួកគេ ។ សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការជាមួយមនុស្សនេះដើម្បីផ្លាស់ប្ដូរអាកប្បកិរិយារបស់ទ្រង់ ។ សូមរៀបចំខ្លួនរួចជាស្រេចដើម្បីជួយនៅពេលដែលមនុស្សមករកអ្នកឱ្យជួយ ។ វាមានសារៈសំខាន់ណាស់ដើម្បីចែកចាយសេចក្ដីស្រលាញ់របស់អ្នកជាមួយមនុស្សដូចនេះធ្វើដូច្នេះពួកគេអាចមើលឃើញថា ព្រះយេស៊ូពិតជាធ្វើអោយជីវិតរបស់មនុស្សផ្លាស់ប្ដូរមែន ។

### ឃ. កុំអធិប្បាយ ឬក៏ ប្រកែកគ្នា

នៅពេលដែលអ្នកកំពុងតែចែកចាយជាមួយអ្នកដទៃ នូវអ្វីដែលព្រះគ្រីស្ទបានធ្វើនៅក្នុងជីវិតរបស់អ្នក សូមកុំអធិប្បាយអោយមនុស្សដទៃនោះ ។ កុំនាំមកជាមួយនូវអាកប្បកិរិយា " ខ្ញុំប្រសើរជាងអ្នក ។ " កុំប្រាប់មនុស្សនូវអ្វីដែលគាត់ធ្វើខុស ឬក៏ ថា គាត់កំពុងតែដើរនៅលើផ្លូវមួយដែលនាំគាត់ទៅកាន់ឋាននរកហើយ ។ សូមចែកចាយនូវសារដែលវិជ្ជមាន ។ ចែកចាយអ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់អ្នក ។ សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញអោយគាត់ឃើញពីកំហុសនៃអំពើបាបរបស់គាត់ ។

## ខ. របៀបចាប់ផ្ដើមប្រើជំហានទាំង ៥

គំនិតនៅខាងក្រោមនេះត្រូវបានរៀបចំឡើងដើម្បីជួយអ្នកអោយចាប់ផ្ដើមអនុវត្តន៍ជំហានទាំង ៥ ដើម្បីអោយក្លាយទៅជាគ្រីស្ទបរិស័ទប្រកបទៅដោយជ័យជំនះ ។

### ១. ជ្រើសរើសផ្នែកនៃអត្ថបទព្រះគម្ពីរដែលមានអត្ថន័យ

ផ្នែកនៃអត្ថបទព្រះគម្ពីរដែលមានអត្ថន័យគឺជាផ្នែកមួយដែលទាក់ទងដោយផ្ទាល់ទៅនឹងសំនួរ, បញ្ហា ឬក៏ ចំណាប់អារម្មណ៍ពិសេសណាមួយដែលអ្នកមាន ។

### ២. ចំណាយពេលវេលាចងចាំអត្ថបទព្រះគម្ពីរ

សូមបង្កើតគោលដៅខ្លះៗសំរាប់ខ្លួនអ្នកផ្ទាល់ ថាតើខ គម្ពីរប៉ុន្មានអ្នកនឹងចងចាំរាល់សប្ដាហ៍ ឬក រាល់ខែ ។ សូមព្យាយាមចំណាយពេលវេលាបន្ថែមទៀតនៅលើការចងចាំអត្ថបទព្រះគម្ពីរនៅការថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ ។ សូមមើលអេសាយ ៥៨:១៣-១៤ ។

## ៣. សូមចំណាយពេលវេលាសញ្ជឹងគិតនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់

ការសញ្ជឹងគិតមានមូលដ្ឋាននៅលើគំនិតនៃការសំលឹងមើលជីវិតតាមរយៈទស្សនៈរបស់ព្រះជាម្ចាស់ ។ តើព្រះអង្គគិតយ៉ាងដូចម្តេចអំពីបញ្ហានេះ? តើព្រះអង្គមានអារម្មណ៍យ៉ាងដូចម្តេចដែរអំពីកិច្ចការនេះ? អ្នកអាចចំណាយពេលនៅក្នុងព្រះពន្ទូលរបស់ព្រះជាម្ចាស់មុនពេលចូលគេងដោយសារតែគំនិតសំខាន់ចុងក្រោយនៅក្នុងចិត្តគំនិតរបស់អ្នកនៅពេលល្ងាចនៅតែនៅក្នុងចិត្តគំនិតរបស់អ្នកពេញមួយយប់ និង ជួយបង្កើតអាកប្បកិរិយារបស់អ្នកសំរាប់ថ្ងៃបន្ទាប់ផងដែរ ។ សូមមើលទំនុកតម្កើង ៦៣:៧-៨ ។

## ៤. គិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពេលដែលអ្នកកំពុងតែធ្វើកិច្ចការដែលមិនតំរូវអោយគិតច្រើន

ចោទិយកថា ៦:៧... បង្ហាញពេលវេលា ៤ ដងនៅក្នុងកំឡុងពេលថ្ងៃ នៅពេលដែលយើងអាចគិត និង និយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

ក) នៅពេលដែលអ្នកនៅផ្ទះ ។ នៅពេលបាយ ។ នៅពេលដែលអ្នកសំរាក ឬក៏ ធ្វើការ ។

ខ) នៅពេលដែលអ្នកចេញក្រៅដើរកំសាន្តលេង( ជិះឡាននៅក្នុងឡាន ឬក៏ ជិះរទេះភ្លើង)

គ) នៅពេលចូលគេង

ឃ) កិច្ចការដំបូងនៅពេលព្រឹក

## ៥. សូមជំនួយពីមិត្តម្នាក់ ឬក៏ ពីរនាក់របស់អ្នក

វាងាយស្រួលធ្លាក់ទឹកចិត្តណាស់ជាមួយនឹងគំរោងដូចនេះ ប្រសិនបើអ្នកធ្វើវាទាំងអស់ដោយម្នាក់ឯងនោះ ។ ប្រសិនបើអ្នកមាននរណាម្នាក់និយាយជាមួយនោះ កិច្ចកានេះនឹងលើកទឹកចិត្តអ្នកអោយបន្តទៅទៀត ។ សូមបង្កើតគោលដៅជាមួយមិត្តភក្តិ និង ត្រួតពិនិត្យគ្នាទៅវិញទៅមកដើម្បីមើលឃើញថាអ្នកសំរេចកិច្ចការនោះ ។

នេះគឺជាអត្ថបទព្រះគម្ពីរខ្លះៗដែលនឹងជួយអ្នកអោយរៀនគំនិត, គោលដៅ និង ព្រះទ័យរបស់ព្រះជាម្ចាស់ ។

| | |
|---|---|
| ម៉ាថាយ ៥-៧ | កូឡូស ៣ |
| យ៉ូហាន ១៥ | ១ ថេស្សាឡូនិក ៤ |
| ១ កូរិនថូស ១៣ | ហេព្រើ ១២ |
| រ៉ូម ៦-៨ | យ៉ាកុប ១ |
| កាឡាទី ៥ | |

ការរីកចំរើនដែលអ្នកពិសោធន៍ជាគ្រីស្តបរិស័ទនាំមកនូវការស្កប់ចិត្តយ៉ាងពិតប្រាកដចំពោះដួងចិត្តរបស់អ្នក ។ ជោគជ័យពិតប្រាកដនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់នាំមកនូវសន្តិភាពពិតប្រាកដនៅខាងក្នុង ទោះបីជាជីវិតគ្រោតគ្រាតប៉ុណ្ណាក៏ដោយ ។ នៅក្នុងផ្នែកនេះយើងបាននិយាយអំពីកិច្ចការផ្សេងៗគ្នាជាច្រើនដែលអ្នកអាចធ្វើដើម្បីរីកចំរើនខាងព្រលឹងវិញ្ញាណខាងគិតគំនិតស្មារតី និង ខាងអារម្មណ៍ ។ យ៉ាកុប ១:២-៤ និង រ៉ូម ៥:៣-៥ លើកទឹកចិត្តយើងអោយទទួលយកនូវកិច្ចការលំបាកៗនៅពេលដែលការលំបាកនោះចូលមក ពីព្រោះព្រះជាម្ចាស់នឹងប្រើការលំបាកទាំងនោះដើម្បីបង្កើតចរិកលក្ខណៈ និងកំលាំងនៅខាងក្នុងយើង ។

**រ៉ូម ៥:៣-៥**

**(៣) មិនតែប៉ុណ្ណោះសោត នៅពេលយើងរងទុក្ខវេទនា យើងនៅតែខ្ពស់មុខដដែលព្រោះយើងដឹងថា ទុក្ខវេទនានឹងនាំអោយយើងចេះអត់ធ្មត់ (៤) ការអត់ធ្មត់នាំអោយយើងចេះស៊ូទ្រាំ ហើយការស៊ូទ្រាំនាំអោយយើងមានសេចក្ដីសង្ឃឹម ។ (៥) សេចក្ដីសង្ឃឹមមិនធ្វើឱ្យយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យ ស្រលាញ់របស់ព្រះអង្គមកក្នុងចិត្តយើងដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង ។**

នៅក្នុងការរីកចំរើនទាំងអស់នេះ អ្នកត្រូវតែធ្វើកិច្ចការដើម្បីបង្កើតឡើងនូវភាពស្មោះត្រង់ និង ការបង្ហាញអោយឃើញនៅក្នុង ។ ក្នុងនាមជាគ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យមិនមែនមានន័យថា អ្នកស្តាប់បង្គាប់យ៉ាងប្រុងប្រយត្ន័នូវវិន័យទាំង ៦៥០របស់ព្រះជាម្ចាស់រាល់ថ្ងៃនោះទេ ។ ជោគជ័យពិតប្រាកដមានន័យថាការផ្លាស់ប្តូរនៅខាងក្នុង ដូច្នេះ អ្នកស្តាប់បង្គាប់តាមវិន័យរបស់ព្រះជាម្ចាស់ដោយសារតែអ្នកចង់ ។ តំលៃផ្ទាល់ខ្លួនរបស់អ្នកត្រូវតែដូចគ្នាទៅនឹងអ្វីៗដែលព្រះយេស៊ូគ្រីស្តមាន ។

វាមិនអាចទៅរួចនោះទេ ក្នុងការក្លាយទៅជាមនុស្សដែលព្រះជាម្ចាស់ចង់អោយអ្នកក្លាយទៅជាតាមរយៈកំលាំង ឬការងារផ្ទាល់ខ្លួនរបស់អ្នកនោះទេ ។ ទោះបីជាអ្នកខិតខំធ្វើការខ្លាំងប្លាក៏ដោយ ក៏អ្នកនឹងនៅតែខ្វះនូវអ្វីដែលព្រះអង្គចង់បាន ។ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់បានផ្តល់នូវព្រះវិញ្ញាណអោយក្លាយទៅជាគ្រូ, អ្នកដឹកនាំ, អ្នកណែនាំ និង ជាអ្នកជំនួយរបស់អ្នក ។ ដោយមានជំនួយរបស់ព្រះអង្គ អ្នកអាចប្រឈមមុខជាមួយនឹងការទុកចិត្តរាល់ថ្ងៃ ។ ទ្រង់នឹងផ្តល់អោយអ្នកនូវកំលាំងដើម្បីប្រឈមមុខទៅនឹងការលំបាកនីមួយៗដែលចូលមកនៅក្នុងផ្លូវរបស់អ្នកនៅពេលដែលអ្នកទុកចិត្តទ្រង់ ។

នៅពេលដែលអ្នកបរាជ័យ សូមសារភាពបរាជ័យនោះ ។ កុំបោកប្រាស់ខ្លួនឯងដោយជឿថាគ្រីស្តបរិស័ទចាស់ទុំមិនដែលធ្វើអំពើបាបនោះទេ ។ គ្រីស្តបរិស័ទចាស់ទុំក៏ធ្វើអំពើបាបដែរ ។ កំណត់សំគាល់ពិតប្រាកដនៃភាពជាចាស់ទុំត្រូវបានបង្ហាញដោយវិធីដែលអ្នកឆ្លើយតបចំពោះបរាជ័យ ។ អ្នកសារភាពបរាជ័យនោះទោះបីជាគ្មាននរណាម្នាក់មើលឃើញបរាជ័យ ឬក៏ អំពើបាបអ្នកក៏ដោយ ។ អ្នកសារភាពអំពើបាបដោយសារតែការបង្ហាញអោយឃើញតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធនៅខាងក្នុងអ្នក មិនមែនដោយសារសំពាធពីខាងក្រៅនោះទេ ។ ភាពចាស់ទុំពិតប្រាកដគឺត្រូវបានបង្ហាញនៅក្នុងជីវិតរបស់អ្នកនៅពេលដែលអ្នកផ្តល់នូវតំលៃដល់ព្រះវិញ្ញាណដ៏វិសុទ្ធសំរាប់អ្វីដែលទ្រង់កំពុងតែធ្វើនៅក្នុងជីវិតរបស់អ្នក ។

# ជំពូក ទី ៣
# ព្រះវិញ្ញាណដ៏វិសុទ្ធ

នៅក្នុងមុខវិជ្ជានេះ យើងបាននិយាយជាច្រើនអំពីព្រះវិញ្ញាណដ៏វិសុទ្ធ និង ផ្នែករបស់ទ្រង់ក្នុងការជួយយើងឱ្យក្លាយជាគ្រីស្ទបរិស័ទប្រកបទៅដោយជ័យជំនះ ។ តើអ្នកស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធល្អប៉ុណ្ណា? តើព្រះវិញ្ញាណគឺជាស្រមោលនៅក្នុងគំនិតរបស់អ្នក? នៅលើជញ្ជីង ពី លេខ ១ ដល់ លេខ ១០ តើលេខប៉ុន្មានអ្នកផ្តល់អោយខ្លួនឯងនៅក្នុងការផ្តល់តំលៃថាតើអ្នកស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធល្អប៉ុណ្ណា? សូមអោយយើងមើលអោយកាន់តែជិតតើព្រះវិញ្ញាណគឺជានរណា និង ទ្រង់ធ្វើអ្វីនៅក្នុងជីវិតរបស់យើង?

## ក. តើព្រះវិញ្ញាណដ៏វិសុទ្ធគឺជានរណា?

ព្រះគម្ពីរគឺជាកន្លែងមួយដ៏ល្អបំផុតដើម្បីចាប់ផ្តើមរកអោយឃើញថាតើព្រះវិញ្ញាណដ៏វិសុទ្ធគឺជានរណា ។ នៅក្នុងសញ្ញាចាស់និយាយតិចតួចណាស់អំពីព្រះវិញ្ញាណដ៏សុទ្ធ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ព្រះគម្ពីរសញ្ញាថ្មីមានអ្វីៗជាច្រើនទាក់ទងទៅនឹងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ដំបូង សូមអោយយើងជំរះអោយជ្រះស្រលះពីគំនិតខុសឆ្គងអំពីថាតើព្រះវិញ្ញាណដ៏វិសុទ្ធគឺជានរណា ។

ព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនជាព្រះយេស៊ូទេ។ ព្រះយេស៊ូបានប្រាប់សាវ័ករបស់ទ្រង់ថា បន្ទាប់ពីទ្រង់សុគត និង រស់ឡើងវិញ ទ្រង់នឹងត្រឡប់ទៅឋានសួគ៌ ។ ប៉ុន្តែ ព្រះអង្គមិនអោយអ្នកដើរតាមទ្រង់នៅម្នាក់ឯងនោះទេ ។ ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងមកជួយពួកគេទាំងអស់គ្នា ។ ព្រះយេស៊ូមិនដែលមានព្រះបន្ទូលថា ព្រះអង្គផ្ទាល់គឺជាព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ ។

ព្រះវិញ្ញាណដ៏បរិសុទ្ធមិនមែនជាឈ្មោះមួយទៀតសំរាប់ព្រះជាម្ចាស់ជាព្រះបិតានោះទេ ។ ព្រះយេស៊ូមិនដែលពិពណ៌នាព្រះបវរបិតានៃឋានសួគ៌របស់ទ្រង់ជាព្រះវិញ្ញាណនោះទេ ។ អ្នកសរសេរព្រះគម្ពីរសញ្ញាថ្មីមិនដែលនិយាយថាព្រះវិញ្ញាណដ៏វិសុទ្ធគឺជាមនុស្សដូចគ្នាទៅជាមួយនឹងព្រះជាម្ចាស់ជាព្រះបិតានោះទេ ។ ប៉ុន្តែព្រះគម្ពីរបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ព្រះវិញ្ញាណដ៏វិសុទ្ធគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ជាព្រះបិតា និង ព្រះយេស៊ូគ្រីស្ទ ។

### ១. ព្រះវិញ្ញាណគឺជាតួអង្គព្រះ

ខណ្ឌ័គម្ពីរយ៉ូហានផ្តល់អោយយើង នូវពត៌មានយ៉ាងពិស្តារនៅលើអ្វីដែល ព្រះគ្រីស្ទបានប្រាប់សាវ័ករបស់ទ្រង់អំពីព្រះវិញ្ញាណដ៏វិសុទ្ធ ។ នៅក្នុងយ៉ូហាន ជំពូក ១៣-១៦ ព្រះយេស៊ូប្រាប់ថាព្រះវិញ្ញាណដ៏វិសុទ្ធគឺជាមនុស្សពិតប្រាកដ ។ នៅក្នុង យ៉ូហាន ១៦:៧-១១ ព្រះយេស៊ូបានពន្យល់កិច្ចការពិសេសខ្លះៗដែលព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើនៅក្នុងពិភពលោករបស់យើងបន្ទាប់ពីព្រះយេស៊ូយាងត្រឡប់ទៅឋានសួគ៌វិញ ។

ព្រះវិញ្ញាណមិនមែនជាខ្មោចដែល....អណ្តែតត្រសែតនៅជុំវិញពិភពលោកយើងនេះទេ ។ ទ្រង់គឺជាមនុស្សពិតប្រាកដហើយយើងមិនត្រូវហៅព្រះវិញ្ញាណដ៏វិសុទ្ធ "វា" នោះទេ ។ អេភេសូ ៤:២៩-៣២ ប្រាប់យើងយ៉ាងច្បាស់ថាព្រះវិញ្ញាណដ៏វិសុទ្ធមានអារម្មណ៍--យើងអាចធ្វើអោយព្រះវិញ្ញាណដ៏វិសុទ្ធព្រួយព្រះទ័យបាន ។

### ២. ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះជាម្ចាស់

ចរិកលក្ខណៈមួយនៃចរិកលក្ខណៈជាច្រើនដែលញែកព្រះជាម្ចាស់ចេញពីរបស់មានជីវិតទាំងឡាយគឺថា ទ្រង់មានវត្តមានគ្រប់ទីកន្លែងទាំងអស់នៅពេលតែមួយ ។ រ៉ូម ៨:៩ បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មិនរស់នៅក្នុងអ្នកនោះទេ នុ៎ះមានន័យថា អ្នកមិនមែនជាគ្រីស្តបរិស័ទនោះទេ ។ វិធីតែមួយគត់ដែលព្រះវិញ្ញាណដ៏បរិសុទ្ធអាចរស់នៅក្នុងជីវិតគ្រីស្តបរិស័ទរាប់លាននាក់ នៅពេលជាមួយគ្នាគឺដោយសារតែទ្រង់មានអំណាចមានវត្តមាននៅគ្រប់ទីកន្លែងនៅពេលដូចគ្នា ។

នៅពេលដែលអ្នកបានអានសញ្ញាថ្មីទាំងមូល អ្នកឃើញថា អ្នកសរសេរបានបញ្ជាក់ថាព្រះវិញ្ញាណគឺជាព្រះជាម្ចាស់ មិនមែនជាទេវតា ឬក៏ របស់មានជីវិតដទៃទៀតនោះទេ ។ ២ ពេត្រុស ១:២០-២១ បញ្ជាក់ថា ព្រះវិញ្ញាណដ៏បរិសុទ្ធគឺជាអង្គតែមួយគត់ដែលបាននាំអោយមនុស្សជាច្រើនបានសរសេរកណ្ឌ័របស់ព្រះគម្ពីរឡើង ។

### ៣. ព្រះវិញ្ញាណដ៏បរិសុទ្ធស្មើជាមួយនឹងព្រះជាម្ចាស់ ហើយនិង ព្រះយេស៊ូគ្រីស្ត

ទាំងព្រះយេស៊ូ ទាំងអស់សរសេរកណ្ឌ៏គម្ពីរនៅក្នុងព្រះគម្ពីរមិនបានអោយព្រះវិញ្ញាណមានឋានៈតូចជាងព្រះជាម្ចាស់ជាព្រះបិតានោះទេ ។ ដូចដែលយើងនឹងមើលឃើញនៅក្នុងកណ្ឌ័គម្ពីរដែលនៅសល់ ព្រះវិញ្ញាណ និង ព្រះជាម្ចាស់ជាព្រះបិតា និង ព្រះយេស៊ូអង្គនីមួយៗមានកន្លែងនៃពន្ធ័កិច្ចច្បាស់លាស់រៀងៗខ្លួនជាព្រះ ។ ក៏រិតស្មើគ្នាត្រូវបានបង្ហាញនៅពេលដែលអ្នកសរសេរនិយាយអំពីព្រះវិញ្ញាណ ។ ទ្រង់ពិតជាព្រះ និង មានលក្ខណៈពេញជាព្រះ ។ ទ្រង់មិនមែនជាអនុ ឬក៏ ទី ៣ នោះទេ ។ ទ្រង់ស្មើជាមួយព្រះជាម្ចាស់ជាព្រះបិតា និង ព្រះបុត្រា ។ គ្រីស្តបរិស័ទជាច្រើនហៅការនេះថា ជាព្រះត្រីឯក...
ទាំងបីអង្គនេះមានព្រះជាម្ចាស់ជាព្រះបិតា, ព្រះជាម្ចាស់ព្រះបុត្រា និង ព្រះជាម្ចាស់ជាព្រះវិញ្ញាណដ៏វិសុទ្ធ ។

## ខ. តើព្រះវិញ្ញាណដ៏សុទ្ធធ្វើអ្វីនៅក្នុងជីវិតរបស់អ្នកនៅពេលដែលអ្នកក្លាយជាគ្រីស្តបរិស័ទ?

ទោះបីមុនមនុស្សក្លាយជាគ្រីស្តបរិស័ទ ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើការនៅក្នុងជីវិតរបស់គាត់រួចជាស្រេចទៅហើយ ។ ព្រះជាម្ចាស់ស្រលាញ់អ្នកមានអំពើបាបជាយូរមុននឹងពួកគេជ្រើសរើសឆ្លើយតបចំពោះសេចក្តីស្រលាញ់របស់ទ្រង់ ។

### ១. ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញអ្នកអោយឃើញពីអំពើបាប

នៅពេលដែលអ្នកនៅក្មេងនៅឡើយ ព្រះវិញ្ញាណដ៏វិសុទ្ធបានចាប់ផ្តើមធ្វើអោយអ្នកយល់ដឹងពីអំពើបាប ។ យ៉ូហាន ១៦ : ៦-១១ ចង្អុលបង្ហាញថា ព្រះវិញ្ញាណដ៏វិសុទ្ធកំពុងតែធ្វើការនៅក្នុងពិភពលោក បង្ហាញអោយមនុស្សដឹងនូវអំពើបាបរបស់ពួកគេ និង បង្ហាញពួកគេនូវផ្លូវប្រសើរជាងនោះសំរាប់រស់នៅ ។ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលចំពោះគ្រប់មនុស្សទាំងអស់តាមរយៈមនសិការរបស់ពួកគេ ។ ប្រសិនបើមនុស្សម្នាក់មិនបានវិវរល់ទៅនឹងមនសិការរបស់គាត់ គាត់នឹងអាចទៅដល់កន្លែងមួយដែលគាត់មិនអាចឮនូវតទៅទៀតនូវការប្រាប់អោយដឹងពីព្រះវិញ្ញាណនៅពេលដែលទ្រង់បង្ហាញគាត់នូវកំហុសតាមរយៈមនសិការរបស់គាត់ ។

នៅក្នុងឳកាសខ្លះទៀត ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រើសកម្មភាពដ៏តឹងតែងដើម្បីឱ្យអ្នកមានអំពើបាបចាប់អារម្មណ៍ ។ កិច្ចការ ជំពូក ទី ៩ ពិពណ៌នាពីរបៀប លោក ស៊ូល... ខ្វាក់ភ្នែក និង បានឮសំលេងរបស់ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់

គាត់ ។ យើងចាំបាច់ត្រូវតែប្រុងប្រយត្ន័ យើងត្រូវតែស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ យើងគ្មានការធានាថា ព្រះជាម្ចាស់នឹងប្រើសំពាធខ្លាំងៗដើម្បីមានព្រះបន្ទូលមកកាន់យើងនោះទេ ។ប្រសិនបើយើងស្គាល់សេចក្តីពិត និង ជ្រើសរើសមិនប្រងើយកន្តើយចំពោះការនោះ នុះផលវិបាកធ្ងន់ធ្ងររងចាំយើងហើយ ។

មនុស្សដែលមិនមែនជាគ្រីស្តបរិស័ទត្រូវបានពិពណ៍នានៅក្នុងព្រះគម្ពីរថាជា " អ្នកងងឹតខាងព្រលឹងវិញ្ញាណ ។ " អ្នកមានអំពើបាបមិនយល់អំពីផលវិបាកដ៏ធ្ងន់ធ្ងរនៃអំពើបាបរបស់ពួកគេទេ ។ សាតាំងវាបានបោកបញ្ឆោតពួកគេអោយជឿថាផ្លូវនៃការរស់នៅរបស់ពួកគេគឺត្រឹមត្រូវហើយ ។ ព្រះវិញ្ញាណយាងមកនឹងមានព្រះបន្ទូលប្រាប់អ្នកមានអំពើបាបម្នាក់ៗថា " អ្នកមានកន្លែងទទេមួយនៅខាងក្នុងយ៉ាងជ្រៅ ហើយដែលអ្នកមិនអាចធ្វើអោយស្កប់បាន ។ មានតែព្រះជាម្ចាស់ទេដែលអាចបំពេញនូវកន្លែងទទេខាងក្នុងនោះ ។ " វាប្រហែលជាងាយស្រួលសំរាប់អ្នកចងចាំ អារម្មណ៏គ្មានសង្ឃឹមនៅខាងក្នុងអ្នកមុននឹងអ្នកក្លាយជាគ្រីស្តបរិស័ទ ។

ព្រះវិញ្ញាណបង្ហាញថាគ្រប់មនុស្សទាំងអស់មានអំពើបាប មិនមែនគ្រាន់តែបង្ហាញមនុស្សអាក្រក់ៗនោះទេ .........
រ៉ូម ៣:២៣ ចែងថា គ្រប់មនុស្សទាំងអស់មានអំពើបាប ។ ប្រសិនបើអ្នកមិនទាន់បានក្លាយទៅជាគ្រីស្តបរិស័ទ ហើយនិយាយទៅកាន់ខ្លួនថា " ខ្ញុំគ្មានអារម្មណ៏ដឹងថា ព្រះវិញ្ញាណកំពុងតែបង្ហាញខ្ញុំនូវអំអើបាបនោះទេ " នោះមានន័យថា អ្នកមិនស្តាប់ទ្រង់នោះទេ ។ ប្រសិនបើអ្នកពិបាកយល់ដឹងនូវអំពើបាបអ្វីដែលអ្នកប្រព្រឹត្ត នោះអធិស្ឋាន និង សុំអោយព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់អ្នកអោយច្បាស់នៅខាងក្នុង ធ្វើដូច្នេះ អ្នកនឹងដឹងនៅពេលអ្នកធ្វើអំពើបាប ។

ប៉ុន្តែនៅពេលជាមួយគ្នានេះដែរ កុំតំរូវអោយព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់អ្នកនៅពេលដែលអ្នកដឹងថា អ្នកបានធ្វើខុសនឹងវិន័យមួយរបស់ព្រះជាម្ចាស់ ។ ឧទាហរណ៏ ប្រសិនបើអ្នកលួចលុយខ្លះ (អ្នកមិនបានលួចលុយនោះដោយចៃដន្យនោះទេ គឺអ្នកមានចេតនាលួច) អ្នកដឹងថា អ្នកធ្វើខុសនឹងវិន័យរបស់ព្រះជាម្ចាស់ ។ កុំដោះសារហើយនិយាយថា " វាមិនជាអ្វីទេសំរាប់អោយខ្ញុំលួចនោះ ព្រោះខ្ញុំមិនបានឮព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំ ហើយនិយាយថា ការនោះគឺខុស " ព្រះជាម្ចាស់មានព្រះបន្ទូលរួចទៅហើយនៅក្នុងព្រះគម្ពីរ ។ អ្នកស្គាល់សេចក្តីពិត ឥឡូវនេះអ្នកមានការទទួលខុសត្រូវក្នុងការស្តាប់បង្គាប់កិច្ចការនោះ ។

នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញសេចក្តីពិតនៃនិស្ស័យបាប និង ផលវិបាកដែលអាចបណ្តាលអោយស្លាប់បានរបស់វា ទ្រង់ក៏បានបង្ហាញដល់មនុស្សនូវជំរើស--ជីវិតថ្មីនៅក្នុងព្រះគ្រីស្ត ។ នៅពេលដែលអ្នកសារភាពអំពើបាបរបស់អ្នកព្រះជាម្ចាស់ទ្រង់នឹងអត់ទោសអោយអ្នក ។

## ២. ព្រះវិញ្ញាណដ៏វិសុទ្ធនាំអោយអ្នកទៅឯព្រះគ្រីស្ត

ព្រះវិញ្ញាណដ៏វិសុទ្ធនាំអោយអ្នកចូលទៅជិតព្រះជាម្ចាស់ ។ មនុស្សមានបាបមិនស្វែងរកព្រះជាម្ចាស់នោះទេ ព្រះអង្គស្វែងរកអ្នកមានបាប ។ ព្រះជាម្ចាស់ស្រលាញ់អ្នក និង គ្រប់មនុស្សដទៃទៀតនៅក្នុងពិភពលោកនេះ មុននឹងអ្នកបែរចេញពីអំពើបាបរបស់អ្នក និង ទទួលយកទ្រង់ ។

ព្រះវិញ្ញាណដ៏បរិសុទ្ធនាំអ្នកអោយស្គាល់គ្រប់ទាំងសេចក្តីពិតអំពីជីវិត ។ យ៉ូហាន ១៦:១៣ ចែងថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំអ្នកឱ្យស្គាល់គ្រប់ទាំងសេចក្តីពិតទាំងអស់ មិនមែនតែមួយផ្នែកនៃសេចក្តីពិតនោះទេ ។ កត់សំគាល់ពាក្យ " នាំ "

នោះនិយាយអំពីដំណើរការ ។ ជានិច្ចជាកាល ទ្រង់នឹងមិនផ្ដល់អោយអ្នកនូវគ្រប់ទាំងសេចក្ដីពិតរបស់ទ្រង់នោះទេ ។ ទ្រង់ចង់ឱ្យអ្នកពិសោធន៍សេចក្ដីពិតរបស់ទ្រង់មិនមែនគ្រាន់តែបំពេញខួរក្បាលរបស់អ្នកជាមួយនឹងសេចក្ដីរបស់ព្រះគម្ពីរប៉ុណ្ណោះទេ ។

## ៣. ព្រះវិញ្ញាណដ៏វិសុទ្ធមក និង រស់នៅក្នុងវិញ្ញាណរបស់អ្នក

នៅពេលមនុស្សម្នាក់សំរេចចិត្តថ្វាយជីវិតរបស់គាត់ដល់ព្រះជាម្ចាស់ និង ចាប់ផ្ដើមដើរតាមទ្រង់ ព្រះវិញ្ញាណដ៏វិសុទ្ធមករស់នៅខាងក្នុងជីវិតរបស់យើង។ រ៉ូម ៨:៩ បញ្ជាក់យ៉ាងច្បាស់ថាកិច្ចការនេះគឺជាការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស ។ នៅពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទភ្លាម ព្រះវិញ្ញាណដ៏វិសុទ្ធមករស់នៅក្នុងជីវិតរបស់អ្នក ។ ព្រះអង្គនឹងមិនចាំរយៈពេល ១ ថ្ងៃ, ១ សប្ដាហ៍ ឬក៏ ១ ខែ នោះទេ មុននឹងទ្រង់មករស់នៅក្នុងជីវិតរបស់អ្នក ។ ព្រះអង្គចង់ក្លាយជាផ្នែកដ៏សកម្មនៅក្នុង ជីវិតរបស់អ្នកមិនមែនគ្រាន់តែធ្វើកិច្ចការបង្ហាញអំពើបាបដែលធ្វើនោះទេ ។ ទ្រង់ចង់ជួយអ្នកអោយរីកចំរើនខាងព្រលឹងវិញ្ញាណ និង ក្លាយទៅជាចាស់ទុំខាងព្រលឹងវិញ្ញាណ ។

នៅពេលសង្គ្រោះ មនុស្សម្នាក់ពិសោធន៍ជីវិតថ្មីនៅខាងក្នុង ។ ព្រះវិញ្ញាណដ៏វិសុទ្ធនាំជីវិតថ្មីនេះនៅក្នុងអ្នក ។

រ៉ូម ៨:១១ ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញសណ្ឋិតនៅក្នុងបងប្អូនមែននោះ ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រិស្តអោយមានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏នឹងប្រទានឱ្យរូបកាយរបស់បងប្អូនដែលរមែងតែងតែស្លាប់នេះ មានជីវិតតាមរយៈព្រះវិញ្ញាណដែលសណ្ឋិតនៅក្នុងបងប្អូននោះដែរ ។

ព្រះវិញ្ញាណដ៏វិសុទ្ធមិនយាងមកអង្គុយស្ងាត់ៗនៅក្នុងជីវិតរបស់អ្នក ខណៈពេលដែលអ្នកបន្តធ្វើអ្វីដែលអ្នកចង់ធ្វើពីមួយថ្ងៃទៅមួយថ្ងៃ ។ ព្រះអង្គចង់មានចំណែកមួយដ៏សកម្មនៅក្នុងជីវិតរបស់អ្នក ។ កិច្ចការដំបូងបង្អស់ដែលទ្រង់ចង់ធ្វើគឺឱ្យអ្នកដឹងថាអ្នកគឺពិតជាគ្រិស្តបរិស័ទ ។ **រ៉ូម ៨:១៦ ចែងថា " គឺព្រះវិញ្ញាណផ្ទាល់ដែលផ្ដល់សក្ខីភាពអោយព្រះវិញ្ញាណរបស់យើងដឹងថា យើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់មែន ។ "**

កុំភ្ញាក់ផ្អើលអីប្រសិនបើការសង្ស័យពេញនៅក្នុងជីវិតរបស់អ្នក ។ " ប្រហែលជាខ្ញុំមិនមែនជាគ្រិស្តបរិស័ទនោះទេ ។ តើខ្ញុំអាចដឹងថាកិច្ចការនេះពិតជាអាចដំណើរការសំរាប់ខ្ញុំដោយរបៀបណា? ខ្ញុំមិនឮព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំនោះទេ ។ ខ្ញុំគ្មានអារម្មណ៍ខុសប្លែកនោះទេ ។ " កិច្ចកានេះ និង គំនិតដទៃទៀតប្រហែលជាពេញនៅក្នុងគំនិតរបស់អ្នក និង ព្យាយាមលួចប្លន់នូវទំនុកចិត្តដែលព្រះជាម្ចាស់ចង់ផ្ដល់អោយអ្នក ។ អ្នកត្រូវតែជឿនូវអ្វីដែលព្រះគម្ពីរចែង ។ ប្រសិនបើអ្នកពិតជាសារភាពអស់ពីដួងចិត្តនូវអំពើបាបរបស់អ្នក ហើយសុំអោយព្រះយេស៊ូក្លាយជាអ្នកដឹកនាំនៃជីវិតរបស់អ្នក នោះសូមអ្នកទទួលជាសេចក្ដីពិតសំរាប់ជីវិតរបស់អ្នក ។ សូមឈរអោយជាប់ជាមួយនឹងសេចក្ដីសន្យានៅក្នុងព្រះគម្ពីរ ។

មុនដំបូងប្រហែលជាអ្នកមានបញ្ហាលំបាកក្នុងការឮព្រះវិញ្ញាណនៅពេលទ្រង់មានព្រះបន្ទូលមកកាន់អ្នក ។ កុំរំពឹងឮព្រះសូរសៀងខ្លាំងៗពីព្រះជាម្ចាស់នៅពេលទ្រង់មានព្រះបន្ទូលមកកាន់អ្នក ។ ទ្រង់កំរនឹងធ្វើកិច្ចការនោះណាស់ ។ ប៉ុន្តែទ្រង់នឹងមានព្រះបន្ទូលនៅក្នុងដួងចិត្តរបស់អ្នក ។ វិធីមួយដែលអ្នកអាចរៀនស្ដាប់ទ្រង់អោយបានប្រសើរនោះគឺអធិស្ឋានរាល់ថ្ងៃ " ព្រះវិញ្ញាណ សូមទ្រង់ជួយឱ្យទូលបង្គំឮព្រះសូរសៀងទ្រង់ថ្ងៃនេះ នៅពេលទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំ ។ " អ្នកប្រហែលជាធ្លាប់ស្គាល់រួចមកហើយនូវវិធីដែលទ្រង់បង្ហាញអំពើបាបដែលអ្នកបានធ្វើ ។ ឥឡូវនេះ នៅក្នុងវិធីដូចគ្នានេះដែរ សូមស្ដាប់ទ្រង់ក្នុងការណែនាំអ្នកអោយស្គាល់សេចក្ដីពិតថែមទៀតរបស់ព្រះជាម្ចាស់រាល់ថ្ងៃ ។

## គ. តើព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអ្វីនៅក្នុងជីវិតរបស់អ្នកបន្ទាប់ពីអ្នកបានក្លាយទៅជាគ្រីស្ទបរិស័ទ?

កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធទើបតែចាប់ផ្តើមនៅពេលដែលអ្នកបានជ្រើសរើសក្លាយជាគ្រីស្ទបរិស័ទ ។ ព្រះអង្គចង់ធ្វើច្រើនជាងបង្ហាញពីអំពើបាបរបស់អ្នក ។ ព្រះអង្គនឹងនៅតែជាអ្នកជំនួយ និង ជាគូកនរបស់អ្នកដដែលប្រសិនបើអ្នកអនុញ្ញាតអោយទ្រង់មានឱកាសនោះ ។

### ១. ព្រះវិញ្ញាណជួយអ្នកអោយក្លាយជាគ្រីស្ទបរិស័ទប្រកបនៅដោយជោគជ័យ

មុននឹងអ្នកក្លាយជាគ្រីស្ទបរិស័ទ វិញ្ញាណរបស់អ្នកស្លាប់ ។ ឥឡូវនេះអ្នកបានក្លាយទៅជាគ្រីស្ទបរិស័ទព្រះវិញ្ញាណដ៏វិសុទ្ធបានមករស់នៅក្នុងអ្នក ។ ឥឡូវនេះទ្រង់ចង់ដឹកនាំជីវិតអ្នករាល់ថ្ងៃ និង ដើម្បីជួយអ្នកអោយក្លាយជាគ្រីស្ទបរិស័ទចាស់ទុំ ។ ទ្រង់ចង់អោយអ្នកចាប់ផ្តើមអនុវត្តន៍ការរបស់ទ្រង់នៅក្នុងគ្រប់ទាំងកន្លែងនៅក្នុងជីវិតរបស់អ្នក ។ អ្នកអាចចាប់ផ្តើមពិសោធន៍អំណរនៃការសង្គ្រោះរបស់ទ្រង់ ។

**រ៉ូម ៨:៦-៨**

**(៦) ការគិតខាងលោកីយ៍នាំអោយស្លាប់ រីឯការគិតខាងព្រះវិញ្ញាណនាំអោយមានជីវិត និង សេចក្តីសុខសាន្តវិញ**

**(៧) ដ្បិតការគិតខាងលោកីយ៍ទាស់នឹងព្រះជាម្ចាស់ ព្រោះលោកីយ៍ពុំចុះចូលនឹងវិន័យរបស់ព្រះជាម្ចាស់ទេ ហើយថែមទាំងគ្មានសមត្ថភាពនឹងចុះចូលបានផងដែរ ។ (៨) អស់អ្នកដែលនៅខាងលោកីយ៍ ពុំអាចគាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ។**

ឥឡូវនេះអ្នកបានក្លាយទៅជាគ្រីស្ទបរិស័ទហើយ អ្នកនឹងយល់ឃើញថា អ្នកប្រឈមមុខទៅនឹងការសំរេចចិត្តជាច្រើននៅក្នុងប៉ុន្មានខែខាងមុខនេះ ។ តើអ្នកនឹងធ្វើអ្វីដែលអ្នកចង់ធ្វើនោះទេ? ឬ អ្នកនឹងជ្រើសរើសធ្វើអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ? ផ្នែកខ្លះនៃជីវិតរបស់អ្នកនឹងចង់បន្តតាមទំលាប់ និង អាកប្បកិរិយាចាស់ ។ ចំណង់ចាស់របស់អ្នកនឹងមិនបាត់ទៅណាភ្លាមៗនោះទេ ។ ប៉ុន្តែ ព្រះជាម្ចាស់នឹងផ្តល់កំលាំងដល់អ្នកដើម្បីអោយអ្នកលះបង់ផ្លូវចាស់ដែលពេញទៅដោយអំពើបាប និង បំពាក់នូវអាកប្បកិរិយាថ្មី និង ឆ្លើយតបដែលសំគាល់ជីវិតនៃគ្រីស្ទបរិស័ទពេលដោយសេចក្តីជំនឿ ។

### ២. ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអោយអ្នកយល់ដឹងពីសេចក្តីពិតរបស់ព្រះជាម្ចាស់

ឥឡូវនេះ អ្នកបានក្លាយជាគ្រីស្ទបរិស័ទ ការយល់ដឹងរបស់អ្នកនៃសេចក្តីពិតរបស់ព្រះជាម្ចាស់ត្រូវតែធ្វើឱ្យប្រសើរ ។ ព្រះគម្ពីរសន្យាថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំអោយស្គាល់សេចក្តីពិតគ្រប់ទាំងអស់ ។ សូមមើល យ៉ូហាន ១៦:១៣ ។ ប្រសិនបើអ្នកចង់រៀនពីរបៀបក្លាយទៅជាមនុស្សមានជ័យជំនះ នុះអ្នកត្រូវតែរៀនពីព្រះគម្ពីរ ការបង្រៀនដែលបង្ហាញអ្នកពីរបៀបព្រះជាម្ចាស់ចង់អោយអ្នករស់នៅ ។

ព្រះគម្ពីរពេញទៅដោយការទូន្មានដ៏មានប្រយោជន៍ពីរបៀបស្រលាញ់អ្នកដទៃ, បង្ហាញចិត្តសប្បុរស, ដោះស្រាយជាមួយនឹងកំហឹង និង សេចក្តីភ័យខ្លាចរបស់អ្នក, ពីរបៀបរៀបចំទុកដាក់លុយកាក និង ពេលវេលារបស់អ្នកប្រកបដោយភាពវៃឆ្លាត, ពីរបៀបក្លាយទៅជាឪពុកម្តាយដ៏ល្អ, ពីរបៀបចុះសម្រុងជាមួយនឹងមនុស្សដែលពិបាកនឹងចុះសម្រុង និង មានច្រើនទៀតនៅក្នុងព្រះគម្ពីរ ។ យើងត្រូវតែបង្កើតអោយមានពេលវេលាទៀងទាត់មួយដើម្បីសិក្សាព្រះគម្ពីរ និង សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនយើងនៅពេលដែលយើងធ្វើកិច្ចការនេះ ។

## ៣. ទ្រង់នឹងជួយអ្នកប្រឆាំងទៅនឹងការល្បួង

កុំមានការភ្ញាក់ផ្អើលនៅពេលដែលសាតាំងល្បួងអ្នកអោយធ្វើអំពើបាប ។ វានឹងធ្វើអ្វីៗទាំងអស់នៅក្នុងអំណាចរបស់វាដើម្បីបំផ្លាយទំនាក់ទំនងថ្មីរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ ប៉ុន្តែអ្នកមិនចាំបាច់ភ័យខ្លាចទៅនឹងការល្បួងទាំងអស់នោះទេ ព្រះគម្ពីរពេញទៅដោយសេចក្តីសន្យាថា ព្រះជាម្ចាស់នឹងជួយអ្នក នៅពេលដែលការល្បួងមក ។ អ្នកមិនចាំបាច់ស្តាប់បង្គាប់សេចក្តីល្បួងនោះទាំងអស់នោះទេ ។

**រ៉ូម ៨:១២-១៣**

**ហេតុនេះបងប្អូនអើយ យើងមានជំពាក់ម្យ៉ាងតែមិនជំពាក់ខាងលោកីយ៍ដើម្បីរស់តាមលោកីយ៍ទៀតឡើយ ។ ប្រសិនបើបងប្អូនរស់តាមលោកីយ៍ បងប្អូននឹងត្រូវស្លាប់ជាមិនខានផុយទៅវិញ ប្រសិនបើបងប្អូនពឹងផ្អែកលើព្រះវិញ្ញាណ ដើម្បីរំលាយរបៀបរស់នៅតាមលោកីយ៍បងប្អូនមុខតែមានជីវិត ។**

**ព្រះជាម្ចាស់បានសន្យាថា នឹងមានផ្លូវដើម្បីគេចចេញ នៅពេលដែលការល្បួងអោយធ្វើអំពើបាបចូលមក ។ សូមមើល ១ កូរិនថូស ១០:១៣ ។ ព្រះគម្ពីរបានចង្អុលបង្ហាញថា ព្រះជាម្ចាស់នឹងប្រើរាល់ការសាកល្បង និង បញ្ហា** អោយចូលមកក្នុងដំណើរជីវិតរបស់អ្នកដើម្បីបង្កើតចរិកលក្ខណៈ និង កំលាំងខាងក្នុងអ្នកដែលសំគាល់អំពីគ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យ ។ សូមមើល យ៉ាកុប ១:២-៤ និង រ៉ូម ៥:៣-៥ ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកអោយបំពេញសេចក្តីការ និង ចំណង់របស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់ ដូច្នេះអ្នកនឹងមិនត្រូវការធ្វើតាមការល្បួងរបស់អារក្សសាតាំងនោះទេ ។

ប៉ុន្តែសូមអោយយើងដឹងថា គ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ សូម្បីតែគ្រីស្តបរិស័ទដ៏ឧត្តុងឧត្តមបំផុតធ្វើអោយព្រះជាម្ចាស់ខកព្រះទ័យ និង ធ្វើតាមការល្បួងខ្លះផងដែរ ។ ព្រះជាម្ចាស់យាងមកគោះស្មាហើយប្រាប់ថា " ការនោះវាមិនអីទេ " ខ្ញុំមិនរំពឹងថាអោយអ្នកក្លាយជាមនុស្សដ៏ល្អឥតខ្ចោះនោះទេ ។ សូមអោយមានសំណាងល្អពេលក្រោយ ។ " អំពើបាបគឺនៅតែជាអំពើបាប ។ អ្នកត្រូវតែសារភាពអំពើបាបរបស់អ្នក និង ចេញអោយឆ្ងាយពីការនោះ ។ សាតាំងនឹងផ្តន្ទាទោសអ្នកហើយព្យាយាមអោយអ្នកលះបង់ភាពជាគ្រីស្តបរិស័ទរបស់អ្នក ។ ប៉ុន្តែសូមអោយយើងមើលអោយច្បាស់នៅសេចក្តីសន្យាដែលបានផ្តល់ជូននៅក្នុង រ៉ូម ៨ ។

**រ៉ូម ៨:១-២ និង ៤**

**ឥឡូវនេះ អស់អ្នកដែលចូលរួមជាមួយព្រះគ្រីស្តយេស៊ូ ឥតមានទោសពៃរ៍ទៀតឡើយ ដ្បិតវិន័យរបស់ព្រះវិញ្ញាណដែលផ្តល់ជីវិតក្នុងអង្គព្រះគ្រីស្តយេស៊ូ បានរំដោះខ្ញុំអោយរួចផុតពីបាប និង ពីសេចក្តីស្លាប់ ។ ព្រះអង្គធ្វើដូច្នេះ ដើម្បីប្រោសយើងអោយបានសុចរិត ស្របតាមការតំរូវរបស់វិន័យគឺចំពោះយើងដែលមិនរស់នៅតាមលោកីយ៍ តែរស់នៅតាមព្រះវិញ្ញាណវិញ្ញាណ ។**

យើងមានការទទួលខុសត្រូវក្នុងការរស់នៅក្នុងជីវិតមួយបរិសុទ្ធ--លះបង់អំពើបាបរបស់យើងចេញ និង ធ្វើអ្វីដែលព្រះជាម្ចាស់ប្រាប់យើងនៅក្នុងព្រះគម្ពីរអោយធ្វើវិញ។ គ្រប់គ្រីស្តបរិស័ទទាំងអស់ប្រឈមមុខទៅនឹងការល្បួង និង ការទទួលខុសត្រូវដ៏សំខាន់មួយ នៅក្នុងចំណោមការទទួលខុសត្រូវដ៏សំខាន់ជាច្រើនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធគឺប្រាប់យើងអោយដឹងមុននូវគ្រោះថ្នាក់ខាងមុខ និង បង្ហាញផ្លូវរបស់ព្រះជាម្ចាស់ដល់យើងក្នុងចេញអោយឆ្ងាយពីការល្បួង ។ ប្រសិនបើយើងប្រងើយកន្តើយសំលេងស្ងាត់ស្ងៀមរបស់ទ្រង់ និង បន្តធ្វើអំពើបាប នោះព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រាប់យើងអោយដឹងពីអំពើបាបរបស់

យើង ។ ទ្រង់នឹងជួយយើងអោយរីកចំរើនតាមរយៈជោគជ័យ និង បរាជ័យរបស់យើង ប្រសិនបើយើងសុខចិត្តអោយទ្រង់បង្រៀនយើង ។

## ៤. ទ្រង់បង្កើតផលផ្លែព្រះវិញ្ញាណនៅក្នុងជីវិតរបស់អ្នក

មានកន្លែងជាច្រើននៅក្នុងសញ្ញាថ្មីពិពណ៌នាពីដំណើរការក្នុងការក្លាយជាគ្រីស្ទបរិស័ទដែលប្រកបទៅដោយជោគជ័យដូចជាការដោះចោលជីវិតចាស់ និង បំពាក់ជីវិតថ្មីវិញ ។ ព្រះជាម្ចាស់ចង់អោយអ្នកក្លាយទៅជាជីវិតថ្មីទាំងស្រុង ។ តើនោះមានន័យថា អ្នកនឹងបញ្ឈប់ធ្វើជាខ្លួនអ្នកផ្ទាល់ និងជាមនុស្សម្នាក់ផ្សេងមួយទៀត ។ មិនមែនទេ ។ វាមានន័យថា ការដោះចោលទំលាប់ និង អាកប្បកិរិយានៃអំពើបាបចាស់ចេញ ហើយជំនួសកិច្ចការទាំងនោះជាមួយនឹងគុណភាពចរិកលក្ខណៈដែលនឹងធ្វើអោយអ្នកដូចព្រះគ្រីស្ទថែមទៀត និង អាកប្បកិរិយា និង ទំលាប់ដែលទ្រង់មាននៅពេលទ្រង់មានព្រះជន្មនៅលើផែនដី ។ តើគុណភាពដូចព្រះជាម្ចាស់ទាំងនេះគឺជាអ្វី?

កាឡាទី ៥:២២-២៣ ផ្តល់នូវបញ្ជីនៃគុណភាព ៩ និង បានពិពណ៌នាគុណភាពទាំងនោះជា ផលផ្លែនៃព្រះវិញ្ញាណ ។" ប្រសិនបើព្រះវិញ្ញាណត្រូវបានផ្តល់សេរីភាពអោយធ្វើការនៅក្នុងជីវិតរបស់អ្នក បន្ទាប់មក អ្នក និង អ្នកដទៃគួរតែមើលឃើញគុណភាពទាំងនេះច្រើនឡើងៗថែមទៀតពេលច្រើនសប្តាហ៍កន្លងទៅ ។

**កាឡាទី ៥:២២-២៣**

**រីឯផលដែលកើតមកពីព្រះវិញ្ញាណវិញ គឺសេចក្តីស្រលាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោសមេត្តា ជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង ។ គ្មានវិធីណាជំទាស់ទៅនឹងសេចក្តីទាំងនេះទេ ។**

**អ្នកត្រូវតែសហប្រតិបត្តិការជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ ប្រសិនបើអ្នកចង់មើលឃើញគុណភាពទាំងនេះរីកចំរើន** នៅក្នុងជីវិតរបស់ខ្ញុំ ។ ការផ្លាស់ប្តូរនឹងមិនមកដោយស្វ័យប្រវត្តិទេដោយគ្រាន់តែទៅក្រុមជំនុំនោះទេ ។ កាឡាទី ៥:២៤-២៥ ធ្វើអោយចំនុចនោះកាន់តែច្បាស់ ។

**កាឡាទី ៥:២៤-២៥**

**អស់អ្នកដែលបានរួមជាមួយព្រះគ្រីស្តយេស៊ូសុទ្ធតែបានឆ្កាងតណ្ហា និង បំណង់លោភលន់ផ្សេងៗរបស់លោកីយ៍នោះចោលហើយ ។ ប្រសិនបើយើងមានជីវិតដោយសារព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ ។**

ស្វែងរកឱកាសនៅក្នុងថ្ងៃនីមួយៗដើម្បីបង្ហាញ " ផលផ្លែ " នេះនៅក្នុងសកម្មភាពរស់នៅរាល់ថ្ងៃរបស់អ្នក ។ នៅពេលអ្នកនៅផ្ទះ, នៅពេលបាយ, នៅកន្លែងធ្វើការ, សំរាកពេលទំនេរ, ឬក៏ ធ្វើកិច្ចការអ្វីពិសេស, ព្យាយាមប្រុងប្រៀបត្រចៀករបស់អ្នកស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ទ្រង់នឹងនាំអ្នករាល់ថ្ងៃ ធ្វើដូច្នេះ " ផលផ្លែ "នេះនឹងជាការបង្ហាញមួយដ៏មានអំណាចនៃគុណភាពដូចព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នកនៅពេលពួកគេនៅជាប់ជាមួយទ្រង់ ។

## ៥. អ្នកអាចពិសោធន៍ការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះវិញ្ញាណមានព្រះបន្ទូលជាច្រើនកន្លែង នៃអំណោយទានផ្សេងៗគ្នា ដែលព្រះជាម្ចាស់ផ្តល់អោយបុត្រាបុត្រីរបស់ទ្រង់ ។ អំណោយទានមួយនៅក្នុងចំណោមទានទាំងនេះយើងហៅថា ការជ្រមុជនៅក្នុងព្រះវិញ្ញាណ ។ សព្វថ្ងៃ មិនមែនគ្រប់ទាំងក្រុមជំនុំទាំងអស់យល់ស្របគ្នានូវអំណោយទាននេះនោះទេ ឬក៏ ពីរបៀបដែលអំណោយទាននេះត្រូវបានប្រើសព្វថ្ងៃនោះទេ ។ ប្រសិនបើអ្នកមានចំណាប់អារម្មណ៍នៅក្នុងអំណោយទាននេះ ឬក៏ ប្រសិនបើគ្រីស្ទបរិស័ទអ្នកមានទំនាក់ទំនងជាមួយ

កំពុងតែលើកទឹកចិត្តអ្នកអោយអធិស្ឋានទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណ នោះអ្នកត្រូវឈប់ និង ដំបូងត្រូវឆ្លើយសំនួរទាំងនេះសិន ។

តើហេតុអ្វីបានជាខ្ញុំចង់បានការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ?

តើខ្ញុំនឹងធ្វើអ្វីជាមួយការនោះ ប្រសិនបើព្រះជាម្ចាស់ផ្តល់អោយខ្ញុំ?

ប្រសិនបើអ្នកមិនអាចឆ្លើយសំនួរទាំងនោះបានទេ នោះអ្នកចាំបាច់ត្រូវតែសិក្សាព្រះគម្ពីរជាដំបូងសិន និង ស្វែងរកអោយឃើញនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលដើម្បីឆ្លើយតបចំពោះសំនួរទាំងនេះ ។ ព្រះជាម្ចាស់មិនផ្តល់អោយអំណោយទានដល់បុត្រធីតារបស់ទ្រង់ ដោយធ្វើដូច្នេះពួកគេអាចដាក់ជ័យសញ្ញានៅថ្មើ និង និយាយថា " សូមមើលខ្ញុំនេះ!! ខ្ញុំបានឈ្នះមួយទៀតហើយ ។ "

ព្រះជាម្ចាស់ផ្តល់អំណោយទានខាងព្រលឹងវិញ្ញាណដល់បុត្រធីតារបស់ទ្រង់សំរាប់ហេតុផលសំខាន់ពីរយ៉ាងគឺ :

១. ដើម្បីជួយយើងអោយបង្កើតនូវទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយព្រះអង្គ

២. ជួយអោយយើងកាន់តែមានប្រសិទ្ធភាពថែមទៀតនៅក្នុងការធ្វើកិច្ចការសំរាប់ទ្រង់ក្នុងការបំពេញពន្ធកិច្ចដែលទ្រង់ចង់អោយធ្វើបំពេញ

យើងនឹងមើលកិច្ចការពីរនេះម្តងទៀតនៅក្នុងផ្នែកបន្ទាប់ទៀតនៃជំពូកនេះ ប៉ុន្តែឥឡូវនេះ សូមអោយយើងផ្តោតការយកចិត្តទុកដាក់របស់យើងទៅលើរបៀបដែលកិច្ចការទាំងនេះជាប់ទាក់ទងទៅនឹងការជ្រមុជនៅក្នុងព្រះវិញ្ញាណ ។

## គ. តើការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺជាអ្វី?

គ្រីស្តបរិស័ទខ្លះមានការភ័នច្រលំអំពីអំណោយទាននេះដោយខកខានសិក្សាព្រះគម្ពីរ និង ស្វែងរកថាតើមានអត្ថន័យយ៉ាងដូចម្តេចពីការនេះ ។ " តើអ្នកមានព្រះវិញ្ញាណដ៏វិសុទ្ធហើយឬនៅ? " ពួកគេសួរ " តើអ្នកធ្លាប់បានពេញជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធឬទេ? នៅក្នុងករណីទាំងពីរនេះ ប្រហែលជាពួកគេមានន័យថា " តើអ្នកបានទទួលអំណោយទាននៃការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធឬនៅ ?

អំណោយទាននេះមិនមែនដូចគ្នានឹងការសង្គ្រោះនោះទេ ។ ពិតណាស់ ការសង្គ្រោះគឺជាអំណោយទានរបស់ព្រះអង្គដ៏ល្អបំផុតសំរាប់យើង ហើយនិង តំលៃដែលទ្រង់បានបង់សំរាប់អំណោយទាននោះ ។ ព្រះគ្រីស្តបានសុគតនៅលើឈើឆ្កាងដូច្នេះ យើងអាចមានសេរីភាពទទួលយកអំណោយទាននៃការសង្គ្រោះ ។ នៅពេលទទួលការសង្គ្រោះ ព្រះវិញ្ញាណយាងមករស់នៅក្នុងមនុស្សនោះ ។ ដូច្នេះ នៅពេលនរណាម្នាក់សួរ " តើអ្នកមានព្រះវិញ្ញាណដ៏វិសុទ្ធឬទេ? " អស់អ្នកណាដែលគ្រីស្តបរិស័ទពិតប្រាកដអាចនិយាយយ៉ាងស្មោះត្រង់ និង ជាមួយនឹងទំនុកចិត្តថា " បាទ ឬ ចាំ ខ្ញុំមាន ។ "

ដូច្នេះការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺជាអ្វី? អ្នកចាំបាច់ត្រូវតែសិក្សាព្រះគម្ពីរខ្លួនអ្នកផ្ទាល់ និង សូមព្រះវិញ្ញាណដ៏វិសុទ្ធអោយនាំអ្នកឱ្យស្គាល់គ្រប់ទាំងសេចក្តីអំពីអំណោយទាននេះ ។ នេះគឺជារបៀបគ្រីស្តបរិស័ទខ្លះនឹងឆ្លើយនឹងសំនួរនោះ ។

ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺជាអំណោយទានខាងព្រលឹងវិញ្ញាណដែលព្រះជាម្ចាស់ផ្តល់ឱ្យបុត្រធីតារបស់ទ្រង់ ។ កិច្ចការជំពូក ទី ២ ប្រាប់ថា លើក ទី មួយព្រះជាម្ចាស់បានផ្តល់អំណោយទាននេះដល់បុត្រធីតារបស់ទ្រង់ បន្ទាប់ពីព្រះគ្រីស្តទ្រង់រស់ឡើងវិញ ។ នៅក្នុងការពន្យល់របស់ពេត្រុសដល់ហ្វូងមនុស្សថ្ងៃនោះ គាត់បានលើកឡើង ពី យ៉ូអែល ២:២៨-៣២

ដែលបានថ្លែងទុកថា ព្រះជាម្ចាស់នឹងចាក់វិញ្ញាណរបស់ទ្រង់នៅលើអ្នករាល់គ្នា ។ អំណោយទាននេះគឺមិនមែនសំរាប់ទុកអ្នកដឹកនាំខាងព្រលឹងវិញ្ញាណដែលពិសេសនោះទេ គឺសំរាប់បុត្រធីតារបស់ទ្រង់ទាំងអស់គ្នា ។

នៅក្នុងកិច្ចការ ជំពូក ទី ២ និង នៅកន្លែងដទៃទៀតជាច្រើននៅក្នុងសញ្ញាថ្មី ភស្តុតាងដែលយើងអាចមើលឃើញដំបូងនៃមនុស្សដែលបាន ទទួលការជ្រមុជខាងព្រលឹងវិញ្ញាណគឺពួកគេបាននិយាយនៅក្នុងភាសាដែលពួកគេមិនដែលបានរៀន ។ អ្វីដែលបានកើតឡើងគឺមនុស្សម្នាក់បានចាប់ផ្តើមអធិស្ឋាន និង សរសើរព្រះជាម្ចាស់ជាមួយនឹងពាក្យសំដីដែលគាត់មិនបានរៀន ។ ព្រះវិញ្ញាណដ៏វិសុទ្ធកំពុងតែមានព្រះបន្ទូល ។ មនុស្សម្នាក់ៗគួរតែអនុញ្ញាតិអោយព្រះវិញ្ញាណដ៏វិសុទ្ធគ្រប់គ្រងពាក្យសំដីរបស់គាត់ ។

តើមានការណាផ្សេងទៀតសំរាប់អំណោយទាននេះដែរឬទេ -- គ្រាន់តែនិយាយតែពាក្យដែលយើងមិនបានរៀន? គ្រីស្តបរិស័ទខ្លះនឹងនិយាយថា " បាទ មានទៀត " អ្នកទៀតនឹងនិយាយថា " ទេ គ្មានកិច្ចការណាទៀតចំពោះអំណោយទាននោះទេ ។ តើមានប៉ុន្មានទៀត? ពួកគេនឹងនិយាយថា ការនិយាយនៅក្នុងភាសាដែលគេមិនបានស្គាល់គឺគ្រាន់តែជាការបង្ហាញមកខាងក្រៅនៃអំណោយទាននេះប៉ុណ្ណោះ ។ វាគឺជាអំណោយទានខាងព្រលឹងវិញ្ញាណ និង ហើយការបង្ហាញដែលសំខាន់នោះគឺនៅក្នុងវិញ្ញាណរបស់យើងដែលមិនអាចមើលឃើញបាន ។ តើអំណោយទាននេះជានិច្ចជាកាលព្យាបាលចំពោះគ្រប់ទាំងបញ្ហាខាងព្រលឹងវិញ្ញានរបស់អ្នកឬទេ? ទេ ។ តាមពិត គ្មានអំណោយទានខាងព្រះជាម្ចាស់ណាមួយអាចដោះស្រាយគ្រប់ទាំងបញ្ហារបស់អ្នកនោះទេ ។

ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺមិនមែនជាអំណោយទានដើម្បីជួយអ្នកអោយមានបទពិសោធន៍ខាងអារម្មណ៍ដ៏អស្ចារ្យនោះទេ -- " អារម្មណ៍ខ្ពស់បំផុតជាមួយព្រះជាម្ចាស់ " ។ គ្រីស្តបរិស័ទជាច្រើនយល់ឃើញថា អំណោយទាននេះនាំឱ្យមានអំណរយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់ពួកគេ ។ នោះគឺជាផលប្រយោជន៍មួយយ៉ាងអស្ចារ្យនៃអំណោយទាននេះ ប៉ុន្តែការនោះមិនមែនជាគោលបំណងដ៏សំខាន់របស់ព្រះជាម្ចាស់ក្នុងការផ្តល់អំណោយទានដល់បុត្រធីតារបស់ទ្រង់នោះទេ ។

ព្រះជាម្ចាស់ផ្តល់អំណោយទាននេះដល់បុត្រធីតារបស់ទ្រង់ដើម្បីបង្កើនជីវិតខាងព្រលឹងវិញ្ញាណរបស់ពួកគេ ។ ការរីកចំរើនខាងព្រលឹងវិញ្ញាណនេះគួរតែមានឥទ្ធិពលដោយផ្ទាល់ក្នុងការរស់នៅប្រចាំថ្ងៃរបស់យើងជាមួយអ្នកដទៃ ។

វាប្រហែលជាពិបាកក្នុងការផ្តល់និយមន័យដ៏ល្អឥតខ្ចោះមួយថាតើអ្វីទៅជាការជ្រមុជខាងវិញ្ញាណ ។ នៅក្នុងវិធីប្រហាក់ប្រហែលគ្នានេះដែរ វាពិបាកផ្តល់នូវនិយមន័យដ៏ពេញលេញមួយថាតើអ្វីទៅគឺជាសេចក្តីស្រលាញ់ ។ សេចក្តីស្រលាញ់វាមានន័យច្រើនជាងការ ថើប, អោប, អារម្មណ៍អាណិត, និង គំនិតដ៏កក់ក្តៅ ។ វាមានន័យច្រើនជាងសកម្មភាពដែលយើងអាចមើលឃើញ ។ ប៉ុន្តែ ប្រសិនបើអ្នកពិតជាស្រលាញ់នរណាម្នាក់ អ្នកនឹងបង្ហាញវាតាមរយៈសកម្មភាពរបស់អ្នក និង អារម្មណ៍របស់អ្នក ។ សេចក្តីស្រលាញ់ដ៏ពិតប្រាកដមានឥទ្ធិពលដល់គំនិតរបស់អ្នក ប៉ុន្តែវាមានន័យច្រើនជាងគំនិតដែលស្រលាញ់នោះ ។

ប្រសិនបើអ្នកពិតជាចង់ដឹងថា តើអ្វីទៅជាសេចក្តីស្រលាញ់ អ្នកត្រូវតែពិសោធន៍ជាមួយកិច្ចការនោះ ។ អ្នកពិសោធន៍កាន់តែច្រើន អ្នកនឹងយល់ដឹងកាន់តែប្រសើរឡើង ។ វាដូចគ្នាទៅនឹងការជ្រមុជនៅក្នុងព្រះវិញ្ញាណដែរ ។ អ្នកមិនអាចយល់ដឹងគ្រប់សព្វកិច្ចការនោះនៅក្នុងចិត្តគំនិតរបស់អ្នកនោះទេ រហូតទាល់តែអ្នកពិសោធន៍ការនោះនៅក្នុងវិញ្ញាណរបស់អ្នក និង ជីវិតរបស់អ្នកទាំងមូល ។

## ខ. តើអ្នកនឹងធ្វើអ្វីជាមួយនឹងអំណោយទាននេះ ប្រសិនបើព្រះជាម្ចាស់ផ្ដល់វាឱ្យអ្នក?

ព្រះជាម្ចាស់គឺជាបិតាដ៏ឆ្លាតវៃ ហើយទ្រង់នឹងមិនផ្ដល់អំណោយទានរបស់ទ្រង់ដោយល្ងង់ខ្លៅដល់បុត្រធីតារបស់ទ្រង់ ហើយអោយពួកគេបំពានអំណោយទានទាំងនោះ នុ៎ះទេ ។ ព្រះជាម្ចាស់ស្រលាញ់យើងខ្លាំងណាស់ និង ចង់បង្ហាញសេចក្ដីស្រលាញ់របស់ទ្រង់ដល់យើង ។ ទ្រង់មានព្រះទ័យចង់ផ្ដល់អោយខ្លាំងណាស់នូវអំណោយទានខាងព្រលឹងវិញ្ញាណដល់អស់អ្នកណាដែលចង់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទ្រង់ ។ ទ្រង់នឹងមិនដែលបង្ខំផ្ដល់អំណោយទានរបស់ទ្រង់ដល់អ្នកនោះទេ។ ប្រសិនបើអ្នកមិនចង់បានការជ្រមុជខាងព្រលឹងវិញ្ញាណ អ្នកនឹងមិនបានទទួលអំណោយទាននោះទេ ។ ហេតុអ្វីបានជាគ្រីស្ទបរិស័ទចង់បានអំណោយទាននេះ? តើអំណោយទាននេះនឹងផ្ដល់ផលប្រយោជន៍ដល់អ្នករបៀបណា?

តើព្រះគម្ពីរមានព្រះបន្ទូលអ្វីនឹងកើតឡើងចំពោះគ្រីស្ទបរិស័ទដែលមានអំណោយទាននេះ? កិច្ចការ ១:៨ ផ្ដល់នូវអំណោយទានមួយដល់អ្នកដែលទទួលបានអំណោយទាននេះ ។ ពួកគេនឹងទទួលបានអំណាចដើម្បីធ្វើបន្ទាល់ពីព្រះយេស៊ូគ្រីស្ទ និង អំណាចសង្គ្រោះរបស់ទ្រង់ចំពោះអ្នកមិនទាន់ក្លាយជាគ្រីស្ទបរិស័ទ ។

ផ្លូវមួយនៅក្នុងចំណោមផ្លូវសំខាន់ជាច្រើនដែលអំណោយទាននេះគួរតែមានឥទ្ធិពលដល់អ្នកគឺដើម្បីជួយអ្នកអោយបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ ។ ប៉ូលសរសេរកន្លែងសំខាន់ដែលអំណោយទាននេះមាននៅក្នុងជីវិតអធិស្ឋានរបស់គាត់ ។ " ខ្ញុំសូមអរគុណព្រះជាម្ចាស់ ព្រោះខ្ញុំចេះនិយាយភាសាចំឡែកអស្ចារ្យអស្ចារ្យលើបងប្អូនទាំងអស់គ្នាទៅទៀត ។ " (១ កូរិនថូស ១៤:១៨)

អំណោយទានក្នុងការនិយាយភាសាចំឡែកអស្ចារ្យដែលអ្នកមិនបានរៀន--អាចជាឧបករណ៍មួយដ៏អស្ចារ្យដែលអាចនាំអោយអ្នកចូលទៅជិតព្រះជាម្ចាស់ ។ ប៉ុន្តែការទទួលខុសត្រូវវាអាស្រ័យនៅលើអ្នកដើម្បីប្រើអំណោយទាននេះអោយបានសមរម្យ ។ មិនមែនដោយសារតែអ្នកមានអំណោយទាននេះមានន័យថាអ្នកប្រសើរជាងគ្រីស្ទបរិស័ទដទៃទៀតនោះទេ។ ប្រសិនបើអំណោយនេះមិនមានឥទ្ធិពលវិជ្ជមាននៅលើទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ នោះអ្នកបរាជ័យក្នុងការប្រើអំណោយទានអោយបានសមរម្យហើយ ។

អំណោយទាននេះគួរតែបង្កើតអោយអ្នកមានចំណង់កាន់តែខ្លាំងឡើងក្នុងការដើរអោយកាន់តែជិតព្រះជាម្ចាស់ ។ អំណោយទាននេះគួរតែជំរុញអោយអ្នកបំបាត់ចោលអាកប្បកិរិយា និង ទំលាប់បាបរបស់អ្នក និង បំពាក់នូវអ្វីៗដែលមកពីព្រះជាម្ចាស់ ។ អំណោយទាននេះគួរតែមានឥទ្ធិពលដ៏ធំសម្បើមនៅលើទំនាក់ទំនងរបស់អ្នកជាមួយមនុស្សដទៃទៀត ។ ពួកគេគួរតែមើលឃើញច្រើនឡើងថែមទៀតនៃសេចក្ដីស្រលាញ់ និង អំណាចពិតប្រាកដដែលព្រះជាម្ចាស់បាននាំចូលមកក្នុងជីវិតរបស់អ្នក ។ ប្រសិនបើអ្នកមិនមែនជាគ្រីស្ទបរិស័ទដែលមានសេចក្ដីស្រលាញ់ច្រើនសំរាប់អំណោយទាននេះទេ នោះអ្នកនឹងបរាជ័យប្រើប្រាស់អំណោយទាននោះអោយបានសមរម្យ ។

នៅពេលដែលអ្នកទទួលយកអំណោយទាននៃការជ្រមុជខាងព្រះវិញ្ញាណ កុំភ្ញាក់ផ្អើលអីប្រសិនបើគ្មានការផ្លាស់ប្ដូរភ្លាមៗកើតឡើងនៅក្នុងជីវិតរបស់អ្នកនោះ ។ ប៉ុន្តែអំណោយទាននេះគួរតែផ្ដល់ឱ្យអ្នកនូវអំណាចដើម្បីរីកចំរើន និង ក្លាយទៅជាមនុស្សដែលមានចរិកលក្ខណៈដូចព្រះគ្រីស្ទ ។ មិនមែនដោយសារតែអំណោយរ៉ាកែតថ្មីមួយធ្វើអោយអ្នកក្លាយទៅជាអ្នកវាយតិន្និសដ៏ប៉ិនប្រសព្វនោះទេ ។ ប៉ុន្តែអ្នកមិនអាចក្លាយទៅជាអ្នកវាយតិន្និសដ៏ប៉ិនប្រសព្វបានទេ ប្រសិនបើអ្នកមិនមានរ៉ាកែតនោះ ។ នៅក្នុងវិធីដូចគ្នានេះដែរ អំណោយទានមកពីព្រះជាម្ចាស់នេះនឹងបើកអោយមានឱកាសជាច្រើនសំរាប់អ្នក

សំរាប់ការរីកចំរើនខាងព្រលឹងវិញ្ញាណ និង ពន្ធ័កិច្ច ។

ឥទ្ធិពលដទៃទៀតដែលអំណោយទាននេះគួរតែមាននៅក្នុងជីវិតរបស់អ្នកគឺដើម្បីជួយអ្នកអោយបង្កើតឡើងនូវអាកប្បកិរិយាដែលអាចទទួលយកការបង្រៀនច្រើនឡើងថែមទៀត ។ អ្នកនឹងចង់រៀនច្រើនឡើងថែមទៀតអំពីព្រះជាម្ចាស់ និង ពីរបៀបដែលអ្នកអាចបំរើទ្រង់អោយបានប្រសើរឡើង ។ ប្រសិនបើអំនួត និង ការប៉ះបោរ និង មានអាកប្បកិរិយា" ខ្ញុំចេះដឹងទាំងអស់ " រីកធំធាត់នៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងបរាជ័យប្រើអំណោយទាននេះទៅតាមវិធីដែលព្រះជាម្ចាស់ចង់អោយអ្នកប្រើ ។

## គ. តើអ្នកអាចទទួលពិធីជ្រមុជរបស់ព្រះវិញ្ញាណដោយរបៀបណា?

គ្មានអ្វីដែលអ្នកអាចធ្វើដើម្បីទទួលយកអំណោយទាននេះពីព្រះជាម្ចាស់បានទេ ។ អ្នកមិនអាចរកបានការសង្គ្រោះ ឬក៏ អំណោយទានរបស់ព្រះជាម្ចាស់ណាមួយនោះទេ ។ ព្រះជាម្ចាស់ផ្តល់អំណោយទានរបស់ទ្រង់ដល់បុត្រធីតារបស់ទ្រង់ ។ ទ្រង់ធ្វើការសំរេចព្រះទ័យ ។ វាអាចទទួលយកបានទេសំរាប់អ្នកអោយព្រះជាម្ចាស់ស្គាល់នូវចំណង់ចំណូលចិត្តរបស់អ្នក ។ ឧបមាថាមានក្មេងតូចម្នាក់ប្រាប់ឪពុកម្តាយរបស់វាថា " កូនមិនចង់បានសៀវភៅណាមួយសំរាប់ថ្ងៃបុណ្យណូអែលនោះទេ។ " តើអ្នកគិតថា ឪពុកម្តាយនឹងស្តាប់នូវអ្វីដែលកូនរបស់គាត់បាននិយាយទេ? ពិតណាស់ ពួកគេស្តាប់នូវអ្វីដែលកូនរបស់គេនិយាយ ។ ពួកគេស្រលាញ់កូនរបស់ខ្លួន និង ចង់ផ្តល់នូវអំណោយដែលជួយដល់កូនរបស់ខ្លួន និង តាមចំណង់ចំណង់ចំណូលចិត្តរបស់វាផងដែរ ។

ព្រះជាម្ចាស់នឹងមិនផ្តល់អំណោយទានរបស់ទ្រង់ទាំងបង្ខំទៅលើបុត្រធីតារបស់ទ្រង់នោះទេ ។ ម្យ៉ាងវិញទៀតអ្នកមិនអាចបង្ខំទ្រង់អោយផ្តល់អោយអ្នកនូវអំណោយទាននេះទេ ។ ជួនកាលកូនទទូចសុំហើយសុំទៀតរហូតទាល់តែឪពុកម្តាយសំរេចចិត្តយកអ្វីដែលកូនចង់បានអោយទៅកូនដើម្បីអោយមានសេចក្តីសុខសាន្តនៅផ្ទះ ។ ប៉ុន្តែព្រះជាម្ចាស់មិនធ្វើតាមការគាប់សង្កត់នោះទេ ។

ប្រសិនបើអ្នកចង់បានអំណោយណាមួយពីព្រះជាម្ចាស់ អាទិភាពដំបូង និង សំខាន់បំផុតនោះគឺ អ្នកខ្លួនឯងត្រូវតែចូលទៅជិតព្រះជាម្ចាស់ជាមុនសិន ។ខិតខំស្តាប់បង្គាប់វិន័យសំខាន់ទាំងពីរនៅក្នុងព្រះគម្ពីរ ។ តើអ្វីអាចសំខាន់ជានេះតទៅទៀតនៅក្នុងជីវិតជាងការស្តាប់បង្គាប់វិន័យសំខាន់ទាំងពីរនេះ? សូមមើល ម៉ាកុស ១២:២៨-៣១ ។

តើនៅកន្លែងណាអ្នកមើលឃើញព្រះយេស៊ូអធិស្ឋានទៅកាន់ព្រះបិតាហើយមានព្រះបន្ទូលថា " សូមព្រះបិតា ផ្តល់អោយទូលបង្គំនូវអំណោយទានថែមទៀតនៅថ្ងៃនេះ ។ " តើអ្នកទៅរកមនុស្សដែលអ្នកស្រលាញ់ហើយនិយាយថា " ខ្ញុំចង់បានអំណោយពីអ្នកថ្ងៃនេះ ។ " ការធ្វើកិច្ចការដូចនេះមិនមែនជាវិធីមួយដើម្បីបង្កើតអោយមានទំនាក់ទំនងជិតស្និទ្ធនោះទេ។ ផ្ទុយទៅវិញ សូមស្វែងរកវិធីដែលអ្នកអាចធ្វើអ្វីដែលព្រះជាម្ចាស់បានប្រាប់អោយអ្នកធ្វើ ។ ប្រសិនបើអ្នកប្រឈមមុខស្ថានភាពដែលអ្នកមិនមានអំណាចធ្វើអ្វីដែលអ្នកដឹងថាព្រះជាម្ចាស់ចង់អោយអ្នកធ្វើ សុំជំនួយមកពីព្រះអង្គ។ ទ្រង់នឹងជួយអ្នក។ ប្រសិនបើអ្នកត្រូវការសេចក្តីស្រលាញ់ច្រើនឡើងថែមទៀត សូមទ្រង់អោយជួយអ្នកស្រលាញ់មនុស្សដែលអ្នកគិតថា ពិបាកស្រលាញ់ ។

ប្រសិនបើអ្នកចង់ចូលទៅជិតទ្រង់ សូមប្រាប់ទ្រង់ ។ ទ្រង់នឹងស្តាប់អ្នក ។ ប្រសិនបើអ្នកចង់មានប្រសិទ្ធភាពច្រើនឡើងថែមទៀតក្នុងការធ្វើជាបន្ទាល់ប្រាប់ទៅអ្នកមិនទៀនជឿ សូមប្រាប់ព្រះជាម្ចាស់ ។ ប្រសិនបើអ្នកចង់បានអំណាចខាង

ព្រលឹងវិញ្ញាណនៅក្នុងជីវិតរបស់អ្នក សុំជំនួយមកពីព្រះជាម្ចាស់ ។ កុំទៅសុំអំណោយទាននោះ ។ ផ្ទុយទៅវិញត្រូវចំណាយពេលចូលទៅជិតទ្រង់ ។ ទ្រង់មានព្រះទ័យពេញចិត្តនឹងបង្ហាញអំណោយទានរបស់ទ្រង់ទៅលើមនុស្សដែលរក្សានូវអាទិភាពខ្លួនរឹងមាំមិនវៀចវេរ ។

## ៦. ទទួលផ្តល់អំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះវិញ្ញាណដ៏វិសុទ្ធចង់ផ្តល់អោយអ្នកនូវអំណាចដើម្បីឱ្យអ្នកក្លាយទៅជាគ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យ ។ ទ្រង់ចង់រៀបចំយើងសំរាប់ពន្ធ័កិច្ច ។ គំនិតនៃពន្ធ័កិច្ចរបស់ព្រះជាម្ចាស់មិនគ្រាន់តែអោយអ្នកក្លាយជាអ្នកអធិប្បាយ ឬក៏បេសកជននោះទេ ។ ព្រះអង្គចង់អោយបុត្រធីតារបស់ទ្រង់ទាំងអស់ធ្វើការដើម្បីទ្រង់ទោះបីជាពួកគេនៅទីណាក៏ដោយ ។ គ្មាននរណាម្នាក់តូចទាបដើម្បីអោយព្រះជាម្ចាស់ប្រើនោះទេ ។ ទ្រង់នឹងណែនាំអ្នក ប៉ុន្តែអ្នកត្រូវតែធ្វើការ ។ នៅពេលដែលអ្នកធ្វើកិច្ចការដែលព្រះជាម្ចាស់បានដាក់ចំពោះមុខអ្នកទ្រង់នឹងផ្តល់ជំនួយដែលអ្នកត្រូវការ ។

អំណោយទានខ្លះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានប្រើនៅក្នុងពន្ធ័កិច្ចសាធារណៈ ។ ១ កូរិនថូស ជំពូក ទី ១២ ផ្តល់នូវការពន្យល់នៃអំណោយទានទាំងនេះ និង របៀបគេប្រើអំណោយទានទាំងនេះ ។

រ៉ូម ១២ និង អេភេសូ ៤ ពន្យល់ព្រះអំណោយទានដទៃផ្សេងៗទៀតដែលព្រះវិញ្ញាណផ្តល់អោយគ្រីស្តបរិស័ទ ។ អំណោយទានទាំងនេះត្រូវបានប្រើនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង និង នៅក្នុងទីកន្លែងធ្វើការរបស់យើង ។ រ៉ូម ៨:៦ ចែងថា ព្រះជាម្ចាស់បានផ្តល់អោយគ្រប់គ្រីស្តបរិស័ទទាំងអស់យ៉ាងហោចណាស់នូវអំណោយទានខាងព្រលឹងវិញ្ញាណមួយ ។ អេភេសូ ៤:១២-១៣ ពន្យល់គោលបំណងនៃអំណោយទានទាំងនេះ ។

**អេភេសូ ៤:១២-១៣**

**ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និង កសាងព្រះកាយរបស់ព្រះគ្រីស្តឡើង ។ រហូតដល់យើងទាំងអស់រួមគ្នា មានជំនឿតែមួយ មានគំនិតតែមួយ ក្នុងការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់ និង ទៅជាមនុស្សពេញវ័យ ឡើងដល់កំពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់ ។**

១ ពេត្រុស ៤ ផ្តល់នូវបញ្ជីខ្លះៗផងដែរនៃអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ មិនថាអ្នកមានអំណោយទានខាងបង្រៀន, ខាងការបង្ហាញសេចក្តីមេត្តាករុណា, ជំនឿ, ការប្រោសអោយជា, រដ្ឋបាល, ឬក៏ អធិប្បាយនោះទេ ព្រះជាម្ចាស់ចង់អោយអ្នកប្រើអំណោយទាននោះដើម្បីជួយអោយអាណាចក្ររបស់ទ្រង់រីកចំរើនឡើង ។ ព្រះអង្គចង់អោយអ្នកប្រើអំណោយទានដើម្បីនាំសិរីរុងរឿងដល់ព្រះជាម្ចាស់មិនមែនសំរាប់ខ្លួនអ្នកនោះទេ ។

ព្រះវិញ្ញាណដ៏វិសុទ្ធចង់មានកន្លែងដ៏ពិសេសនៅក្នុងជីវិតរបស់អ្នក ។ អ្នកជ្រើសរើសថាតើឥទ្ធិពលធំប៉ុណ្ណាដែលទ្រង់នឹងមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ។ ប្រសិនបើអ្នកប្រងើយកន្តើយជំនួយរបស់ទ្រង់ អ្នកនឹងប្រឈមមុខទៅនឹងបរាជ័យនៅលើមូលដ្ឋានដ៏ទៀងទាត់មួយ ។ កិច្ចការដ៏សំខាន់បំផុតដែលអ្នកអាចធ្វើគឺចូលទៅអោយកាន់តែជិតព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ។ នៅពេលដែលអ្នកអានព្រះគម្ពីរ សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនអ្នក ។ សូមស្វែងរកវិធីដ៏មានប្រយោជន៍ដើម្បីបង្ហាញផលផ្លែរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក ។ រៀនស្តាប់ទ្រង់នៅពេលទ្រង់មានព្រះបន្ទូលមកកាន់អ្នកនៅក្នុងដួងចិត្តរបស់អ្នក ។ នោះគឺជាផ្លូវទៅកាន់ជោគជ័យដ៏ពិតប្រាកដ ។